ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# សីលធម៌ពលរដ្ឋវិជ្ជា

សម្រាប់

## កម្រិតមធ្យមសិក្សាបឋមភូមិ

២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៥០៣ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា កម្រិតមធ្យមសិក្សាបឋមភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១ ..**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិ**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ ..**

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិនេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្តីផ្តើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ ..**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ[illegible] ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតមធ្យមសិក្សាបឋមភូមិនេះ បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ សំដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅកម្រិតបន្តដោយពង្រីកវិសាលភាពចំណេះដឹង បំណិនការអប់រំសីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ព្រមទាំងផ្តល់នូវចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យា បំណិនសតវត្សរ៍ទី២១ និងបំណិនសិក្សាពេញមួយជីវិត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃអង្គារ ១៣រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ការអប់រំបណ្តុះបណ្តាលសិស្សានុសិស្សឱ្យមានលក្ខណសម្បត្តិប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែកគឺធ្វើឱ្យពួកគេមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីក្លាយជាពលរដ្ឋពេញលេញសម្រាប់កសាងអនាគតនិងការចូលរួមអភិវឌ្ឍប្រទេសជាតិ។

ការវិវឌ្ឍនៃការកែលម្អកម្មវិធីសិក្សា គឺឆ្ពោះទៅរកគុណភាពអប់រំនិងធ្វើឱ្យមានជីវភាពរស់នៅកាន់តែល្អប្រសើរ ដោយបង្កើនការសិក្សាឱ្យផ្សារភ្ជាប់កម្មវិធីសិក្សាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជា ទាំងមុខវិជ្ជាវិទ្យាសាស្ត្រ ទាំងមុខវិជ្ជាសិក្សាសង្គម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា និងវិនិយោគិនផងដែរ។

កម្មវិធីសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ត្រូវបានរៀបចំឡើងដោយផ្អែកលើកម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានឆ្នាំ២០០៦ កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅឆ្នាំ២០០៦ ស្តង់ដាកម្មវិធីសិក្សាសិក្សាសង្គមឆ្នាំ២០០៦ ការអប់រំប្រឆាំងនឹងអំពើពុករលួយ ការអប់រំស្តីពីពលរដ្ឋសកល ការអប់រំស្តីពីសុវត្ថិភាពចរាចរណ៍ បញ្ចូលការគ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់ជាតិ ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស និងស្ថានភាពអប់រំនៃបណ្តាប្រទេសក្នុងសហគមន៍អាស៊ាន ដូចជាសិង្ហបុរី ម៉ាឡេស៊ី ថៃ។ល។ ដែលធានាឱ្យអ្នកសិក្សាមានសមត្ថភាពចូលរួមក្នុងសកម្មភាពសង្គមនិងបន្តការសិក្សានៅគ្រប់គ្រឹះស្ថានសិក្សានានា ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស។

កម្មវិធីសិក្សានេះបានកែលម្អខ្លឹមសារសំខាន់ៗ លទ្ធផលរំពឹងទុក របាយម៉ោង ការណែនាំអនុវត្ត ការវាយតម្លៃ វិធីសាស្ត្របង្រៀន និងតារាងកម្មវិធីសិក្សាលម្អិតចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ ហើយដែលលទ្ធផលរំពឹងទុកនឹងបង្ហាញដល់គ្រូបង្រៀន មាតាបិតា និងមន្ត្រីអប់រំគ្រប់កម្រិតឱ្យដឹងថា នៅពេលដែលសិស្សបានសិក្សាចប់កម្រិតថ្នាក់នីមួយៗនឹងទទួលបាននូវសមត្ថភាពពេញលេញ។

អនុគណៈកម្មការមុខវិជ្ជាឯកទេសសីលធម៌ពលរដ្ឋវិជ្ជានៅកម្រិតមធ្យមសិក្សាបឋមភូមិ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានជំរុញ បង្កលក្ខណៈឱ្យមានការរៀបចំកម្មវិធីសិក្សាលម្អិតនេះប្រកបដោយជោគជ័យ ហើយអនុគណៈកម្មការនេះរីករាយនឹងទទួលយករាល់មតិកែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូ និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសសីលធម៌ពលរដ្ឋវិជ្ជា**

# មាតិកា


ប្រកាស........................................................................................................ i
បុព្វកថា........................................................................................................ iii
អារម្ភកថា........................................................................................................ iv
មាតិកា........................................................................................................ v
១- សេចក្តីផ្តើម........................................................................................................ 1
២- គោលបំណង........................................................................................................ 1
៣- គោលគំនិតៗសំខាន់ៗ........................................................................................................ 4
៤- របាយម៉ោងសិក្សា........................................................................................................ 4
៥- ការណែនាំអនុវត្ត........................................................................................................ 4
៦- ការវាយតម្លៃ........................................................................................................ 6
៧- តារាងកម្មវិធីសិក្សា........................................................................................................ 8
៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៧........................................................................................................ 8
៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៨........................................................................................................ 15
៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៩........................................................................................................ 22
៨- ឯកសារយោង........................................................................................................ 30
៩- បញ្ជីឈ្មោះគណៈកម្មការ........................................................................................................ 31

## ១- សេចក្តីផ្តើម

ការអប់រំបណ្តុះបណ្តាលសិស្សានុសិស្សឱ្យមានលក្ខណៈសម្បត្តិប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ឱ្យពួកគេមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទាគឺដើម្បីឱ្យពួកគេក្លាយជាពលរដ្ឋពេញលេញសម្រាប់អនាគតក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ។

ទំនោរនៃការអប់រំនៅប្រទេសកម្ពុជា ក៏មិនខុសពីទំនោរនៃការអប់រំនៅប្រទេសទាំងឡាយដែរ។ បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានកំណត់យុទ្ធសាស្ត្រផែនការសំដៅអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនស៊ីចង្វាក់គ្នាលើគ្រប់វិស័យដូចជាការលើកស្ទួយវិស័យកសិកម្ម ការបន្តស្តារនិងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍផ្នែកបច្ចេកទេស និងការងារការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។ ឯការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធាន មនុស្សជាតួនាទីរបស់ការងារអប់រំនៅក្នុងសង្គមជាតិយើង។

ការវិវត្តនៃការកែលម្អកម្មវិធីសិក្សា ឆ្ពោះទៅរកគុណភាពអប់រំ និងធ្វើឱ្យពលរដ្ឋមានជីវភាពរស់នៅកាន់តែល្អប្រសើរដោយបង្កើនការសិក្សាឱ្យផ្សារភ្ជាប់កម្មវិធីសិក្សាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ អាស្រ័យហេតុនេះ ក្រសួងអប់រំយុវជន និងកីឡាបានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជាទាំងមុខវិជ្ជាវិទ្យាសាស្ត្រ ទាំងមុខវិជ្ជាសិក្សាសង្គម ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា វិនិយោគិន ការអភិវឌ្ឍប្រកបដោយចីរភាព និងការរួមរស់នៅជាមួយគ្នាដោយសុខសន្តិភាព។

កម្មវិធីសិក្សាថ្មីមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាក៏ដូចជាមុខវិជ្ជាដទៃទៀតដែរ គឺមិនត្រឹមតែអប់រំសិស្សឱ្យមានតែចំណេះដឹងទេ គឺត្រូវអប់រំតម្លៃ សីលធម៌ សុជីវធម៌ដើម្បីរស់នៅចុះសម្រុងជាមួយអ្នកដទៃនៅក្នុងសង្គម។ ដើម្បីឆ្លើយតបនឹងគោលដៅនៃការអប់រំនេះ កម្មវិធីសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាបានរៀបចំឡើងដោយផ្អែកលើកម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានឆ្នាំ២០០៦ កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅឆ្នាំ២០០៦ ស្តង់ដាកម្មវិធីសិក្សា សិក្សាសង្គមឆ្នាំ២០០៦ ការអប់រំការប្រឆាំងនឹងអំពើពុករលួយ ការអប់រំស្តីពីពលរដ្ឋសកល ការអប់រំស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការបញ្ជ្រាបការគ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់ជាតិ ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំ ណេះទូទៅនិងអប់រំបច្ចេកទេស និងកម្មវិធីសិក្សានៃបណ្តាប្រទេសក្នុងសមាគមន៍ ប្រជាជាតិ អាស៊ុអគ្នេយ៍ដូចជា សិង្ហបុរី ម៉ាឡេស៊ី ថៃ ។ល។ ដែលធានាឱ្យអ្នកសិក្សាមានសមត្ថភាពចូលរួមក្នុងសកម្មភាពសង្គម និងបន្តការសិក្សានៅគ្រប់គ្រឹះស្ថានសិក្សានានាទាំងក្នុងប្រទេស ទាំងក្រៅប្រទេស។

កម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាបឋមភូមិមុខវិជ្ជាសីលធម៌ពលរដ្ឋវិជ្ជា នាពេលបច្ចុប្បន្ន បានបង្ហាញលទ្ធផលសិក្សាដល់គ្រូបង្រៀន មាតាបិតាសិស្ស និងមន្ត្រីអប់រំគ្រប់លំដាប់ឱ្យដឹងថា នៅពេលដែលសិស្សបានសិក្សាចប់កម្រិតថ្នាក់នីមួយៗ ពួកគេនឹងទទួលបានសមត្ថភាពពេញលេញ។

កម្មវិធីសិក្សាលម្អិតមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ មាននរៀបរាប់ពីគោលបំណង ខ្លឹមសារសំខាន់ៗនៃកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា របាយម៉ោងសិក្សា វិធីសាស្ត្របង្រៀន ការវាយតម្លៃ និងតារាងកម្មវិធីសិក្សាលម្អិតសម្រាប់ថ្នាក់ទី៧ដល់ថ្នាក់ទី៩។

## ២- គោលបំណង

គោលបំណងរួមនៃការអប់រំសីលធម៌-ពលរដ្ឋវិជ្ជានៅថ្នាក់ទី៧ ទី៨ ទី៩ គឺការអប់រំសិស្សឱ្យស្គាល់ពីតម្លៃគុណធម៌ មានការទទួលខុសត្រូវលើសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន មានការជឿជាក់លើខ្លួនឯង មានឥរិយាបថវិជ្ជមានជាមួយអ្នកដទៃ មានសីលធម៌ សុជីវធម៌ក្នុងការរស់នៅល្អ ចេះដោះស្រាយបញ្ហានៅក្នុងគ្រួសារ

សហគមន៍ សង្គមជាតិ និងពិភពលោក។ មុខវិជ្ជានេះមានបំណងឱ្យអ្នកសិក្សាចូលរួមថែរក្សាវប្បធម៌ អរិយធម៌ អត្តសញ្ញាណជាតិព្រមទាំងមានចំណេះដឹងអំពីសិទ្ធិមនុស្ស ច្បាប់សំខាន់ៗមួយចំនួនរបស់ប្រទេស។ ការសិក្សាមុខវិជ្ជានេះនឹងធ្វើឱ្យសិស្សមានការយល់ដឹងអំពីជីវភាពរស់នៅក្នុងសង្គម បណ្ដុះការយល់ដឹងនិងក្ដីស្រឡាញ់ចំពោះទឹកដី បណ្ដុះស្មារតីភាពជាពលរដ្ឋសកលដែលមានចរិកលក្ខណៈមូលដ្ឋានចាំបាច់ ក្នុងនាមជាអ្នកកសាងសង្គមប្រជាធិបតេយ្យប្រកបដោយសន្តិភាពសម្រាប់ការរស់នៅក្នុងសង្គមជាតិ និងពិភពលោក។ ផ្ដើមចេញពីការយល់ដឹងពីតម្លៃសីលធម៌ ពីសុខសុវត្ថិភាពនឹងនាំឱ្យសិស្សគោរពប្រតិបត្តិច្បាប់របស់ប្រទេស ដើម្បីចូលរួមថែរក្សាសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ មិនប្រព្រឹត្តអំពើអវិជ្ជមានដែលសង្គមស្អប់ខ្ពើម ព្រមទាំងចូលរួមកសាងវប្បធម៌សន្តិភាព អភិវឌ្ឍសង្គមប្រកបដោយនិរន្តរភាពនិងយល់ដឹងអំពីទំនាក់ទំនងល្អជាមួយពិភពលោក។

តាមរយៈការចូលរួមសកម្មភាពសិក្សា និងការអនុវត្តជាប្រចាំនឹងធ្វើឱ្យសិស្សយល់ដឹងអំពីសកម្មភាពផ្សេងៗក្នុងន័យការពារសុវត្ថិភាព ជីវភាពរស់នៅប្រកបដោយផាសុកភាពខ្លួនឯង ប្រជាជន បរិស្ថានរស់នៅដ៏ល្អ និងឱ្យសិស្សដឹងខ្លួនថាខ្លួនជាសមាជិកម្នាក់របស់សង្គម។

មុខវិជ្ជាសីលធម៌-ពលរដ្ឋមានគោលបំណង៖

- ចូលរួមធ្វើឱ្យគ្រួសារមានសុភមង្គល បណ្ដុះសិស្សឱ្យមានមោទនភាព និងក្ដីស្រឡាញ់ចំពោះសង្គមជាតិ និងប្រទេសនៅក្នុងតំបន់
- បណ្ដុះសិស្សឱ្យមានសមត្ថភាពគិតពិចារណាអំពីលក្ខណៈពិសេសនៃបាតុភូតសង្គមក្នុងតំបន់ និងទំនាក់ទំនងទៅមក ព្រមទាំងបណ្ដុះសមត្ថភាពស្វែងចេញអ្វីដែលបានគិត និងបានស្រាវជ្រាវផងដែរ
- បណ្ដុះសិស្សឱ្យមានចំណាប់អារម្មណ៍ទៅលើកម្មវិធីបុណ្យជាតិនីមួយៗ និងពិចារណាអំពីអត្ថន័យនៃបុណ្យទាំងនោះ
- បណ្ដុះសិស្សឱ្យមានការយល់ដឹងអំពីការបោះឆ្នោត របបនយោបាយ រដ្ឋធម្មនុញ្ញ និងទំនាក់ទំនងរវាងរដ្ឋសភា រដ្ឋាភិបាល និងតុលាការ។

ដើម្បីសម្រេចគោលបំណងរួមនៃការអប់រំសីលធម៌-ពលរដ្ឋវិជ្ជា នៅថ្នាក់ទី៧ ទី៨ និង ទី៩ សិស្សទទួលបានសមាសភាគបី សំខាន់ៗជាមូលដ្ឋានដូចខាងក្រោម៖

### ២.១- វិជ្ជាសម្បទា

- យល់ដឹងពីតម្លៃគុណធម៌សំខាន់ៗ និងបង្ហាញអំពីការរៀបចំខ្លួនប្រកបដោយតម្លៃសីលធម៌
- ស្វែងយល់អំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងរកវិធីដោះស្រាយ
- ស្វែងយល់អំពីការថែទាំសុខភាពផ្លូវចិត្ត និងសារៈសំខាន់នៃការថែទាំសុខភាពផ្លូវចិត្ត
- ស្វែងយល់អំពីបញ្ញា ទំនោរនៃធម្មជាតិមនុស្ស និងតម្លៃ
- មានចំណេះដឹងអំពីច្បាប់ លក្ខខណ្ឌនៃច្បាប់ការងារ សិទ្ធិមនុស្សសំខាន់ៗដូចជា លទ្ធិប្រជាធិតេយ្យ សិទ្ធិពលរដ្ឋ សិទ្ធិនិងទំនួលខុសត្រូវ និងសិទ្ធិបោះឆ្នោត
- យល់ដឹងអំពីទំនាក់ទំនងរវាងសិទ្ធិ និងច្បាប់ សិទ្ធិ និងករណីកិច្ចរបស់ពលរដ្ឋ
- យល់ដឹងពីរចនាសម្ព័ន្ធរដ្ឋាភិបាល ស្ថាប័នតុលាការ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបមជ្ឈការ វិមជ្ឈការនិងវិសហមជ្ឈការ
- ស្គាល់អំពីប្រវត្តិនៃកំណើតសាសនា ជំនឿសាសនាផ្សេងៗ និងយល់ដឹងទំនាក់ទំនងរវាងសាសនា និងសង្គម
- មានចំណេះដឹងអំពីច្បាប់ សិទ្ធិមនុស្ស និងទំនាក់ទំនងសិទ្ធិមនុស្សជាមួយទស្សនវិស័យនៃសាសនា

- ស្វែងយល់ពីឥរិយាបថខ្មែរ ពិធីបុណ្យប្រពៃណីសាសនា ពិធីរៀបអាពាហ៍ពិពាហ៍ ទំនាក់ទំនងមិត្តភាព និងការដោះស្រាយទំនាស់ដោយសន្តិវិធី
- យល់ដឹងអំពីទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសនានានៅលើពិភពលោក។

## ២.២- បំណិនសម្បទា

- ស្គាល់តម្លៃជាមនុស្សដែលមានគុណធម៌ និងការទទួលខុសត្រូវ
- បង្ហាញពីតម្លៃជាមនុស្ស និងមានការទទួលខុសត្រូវក្នុងការរស់នៅ
- មានបំណិនក្នុងការថែទាំសុខភាពផ្លូវចិត្ត និងបញ្ញារបស់ខ្លួន
- អនុវត្តតាមច្បាប់ជាតិនិងអន្តរជាតិ ដើម្បីចូលរួមជួយថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់ និងអភិវឌ្ឍសង្គម
- ប្រើប្រាស់បំណិនរបស់ខ្លួនក្នុងការសម្រេចចិត្តជ្រើសរើសអាជីពនាពេលអនាគតបានត្រឹមត្រូវ
- បង្ហាញពីដំណើរការក្តីរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី
- អនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនជាប្រជាពលរដ្ឋ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ
- វិភាគអំពីសារៈសំខាន់នៃតួនាទីរបស់សាសនានៅក្នុងសង្គម
- បង្ហាញវិធីផ្សេងៗក្នុងការកំសាន្ត ដោយចៀសវាងមិនប្រើប្រាស់គ្រឿងញៀន
- ពណ៌នាការទទួលខុសត្រូវរបស់ស្ថាប័ន នីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ និងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន
- អនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនជាប្រជាពលរដ្ឋ
- មានបំណិនសំខាន់ៗក្នុងការថែទាំសុខភាពផ្លូវចិត្ត ការគ្រប់គ្រងគ្រួសារ សហគមន៍ និងប្រទេសជាតិ
- វិភាគពីសារៈសំខាន់នៃទំនាក់ទំនងល្អជាមួយប្រទេសផ្សេងៗនៅលើពិភពលោក។

## ២.៣- ចរិយាសម្បទា

- ឱ្យតម្លៃលើខ្លួនឯង និងឱ្យតម្លៃដល់អ្នកដទៃ
- ប្រកាន់ខ្ជាប់នូវតម្លៃសីលធម៌ សុជីវធម៌ និងគុណធម៌
- បណ្តុះស្មារតីចូលរួមចំណែកជួយអភិវឌ្ឍសហគមន៍និងសង្គម
- មានការទទួលខុសត្រូវក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយមិនឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ
- ស្រឡាញ់ជីវិតរបស់ខ្លួន និងក្រុមគ្រួសារដោយមិនប្រើប្រាស់គ្រឿងញៀន
- គោរពសេរីភាពនៃជំនឿសាសនារបស់អ្នកដទៃ
- មានសីលធម៌ និងការទទួលខុសត្រូវក្នុងការរស់នៅ
- មានការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមានក្នុងសកម្មភាពរស់នៅជាប្រចាំ
- មានការទទួលខុសត្រូវក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយមិនឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ
- គោរពច្បាប់ សិទ្ធិមនុស្ស និងបំពេញកាតព្វកិច្ចជាប្រជាពលរដ្ឋល្អ
- គោរព ឱ្យតម្លៃសេរីភាពនៃជំនឿសាសនា និងការប្រតិបត្តិសាសនារបស់អ្នកដទៃ
- រក្សាអត្តសញ្ញាណជាតិក្នុងទំនាក់ទំនងជាមួយអន្តរជាតិ។

## ៣- គោលគំនិតសំខាន់ៗ

មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ត្រូវបានកំណត់គោលគំនិតសំខាន់ពីរគឺៈ ស្ថានភាពសង្គមបច្ចុប្បន្ន និងដំណោះស្រាយ ដើម្បីអភិវឌ្ឍសមត្ថភាពសិស្សឱ្យទទួលបានចំណេះដឹង បំណិន ក្នុងការដោះស្រាយបញ្ហានានាក្នុងគ្រួសារ សហគមន៍ សង្គមជាតិ តំបន់ និងពិភពលោក ប្រកបដោយការទទួលខុសត្រូវ។

### ៣.១- ស្ថានភាពសង្គមបច្ចុប្បន្ន

ចំណុចនេះផ្តោតលើប្រធានបទទាក់ទងនឹងៈ

- តម្លៃមនុស្ស និងតម្លៃគ្រួសាររួមមានៈ សីលធម៌ សុជីវធម៌ គុណធម៌ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការសម្រេចចិត្ត តម្លៃបញ្ញា ពលរដ្ឋល្អស្អាតស្អំ សេចក្តីត្រូវការ និងមហិច្ឆតា គោលដៅនិងមធ្យោបាយ ការប្រឆាំងអំពើពុករលួយ
- ទំនាក់ទំនងល្អក្នុងសហគមន៍ដូចជាៈ ការជួយកែលម្អគ្នាជាភារតៈ សុភមង្គលគ្រួសារ សិទ្ធិ និងករណីយកិច្ច សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិរក្សាអត្តសញ្ញាណ កម្មសិទ្ធិ កិច្ចការពារសិទ្ធិរបស់ខ្លួន សាលាដំបូងរាជធានី ខេត្ត ច្បាប់និងសុវត្ថិភាពចរាចរណ៍ជើងគោក ព្រមទាំងកិច្ចការពារបរិស្ថាន
- វប្បធម៌ និងសាសនាដូចជាៈ ទំនាក់ទំនងវប្បធម៌ និងសង្គមធម៌ ស្ថាបត្យកម្មប្រាសាទអង្គរវត្ត
- សង្គមជាតិយើងរួមមានៈ ការងារ និងយុវជន សន្តិភាព និងទំនាស់។

### ៣.២- ដំណោះស្រាយ

ដំណោះស្រាយ និងវិភាគលើបញ្ហាដែលកើតមាននៅក្នុងស្ថានភាពសង្គមបច្ចុប្បន្នខាងលើដែលផ្តោតលើៈ

- ការផ្លាស់ប្តូរផ្នត់គំនិតមនុស្សអវិជ្ជមានទៅជាពលរដ្ឋល្អនិងមានផ្នត់គំនិតទៅរកភាពវិជ្ជមានក្នុងសង្គម
- គ្រួសារ សហគមន៍ សង្គមជាតិ តំបន់ ពិភពលោក នាំឱ្យមានការរស់នៅសុខដុមនីយកម្ម សន្តិភាព និងអភិវឌ្ឍប្រកបដោយនិរន្តរភាព។

## ៤- របាយម៉ោងសិក្សា

| ថ្នាក់ទី | ចំនួនសប្តាហ៍ ក្នុង១ឆ្នាំ | ចំនួនម៉ោង ក្នុង១សប្តាហ៍ | ចំនួននាទី ក្នុងម៉ោងសិក្សា | ចំនួនម៉ោង ក្នុង១ឆ្នាំសិក្សា |
|---|---|---|---|---|
| ៧-៩ | ៣៥ | ២ | ៥០នាទី | ៧០ម៉ោង |

## ៥- ការណែនាំការអនុវត្ត

ដើម្បីអនុវត្តកម្មវិធីសិក្សាសីលធម៌-ពលរដ្ឋ ឱ្យបានជោគជ័យគ្រូត្រូវៈ

- រៀបចំសកម្មភាពរៀន និងបង្រៀនដោយបែងចែកតាមក្រុមនៅក្នុងថ្នាក់
- ដើរតួជាអ្នកសម្របសម្រួល និងជួយសិស្សខ្សោយឱ្យបានច្រើន
- បញ្ជ្រាបតម្លៃការអប់រំពលរដ្ឋសកលនៅគ្រប់សកម្មភាពបង្រៀននិងរៀនតាមមេរៀនទាំងអស់ក្នុងកម្មវិធីសិក្សា

- ណែនាំសិស្សឱ្យចេះអង្កេតតាមលក្ខណៈវិទ្យាសាស្ត្រជាមូលដ្ឋានដើម្បីទទួលបានព័ត៌មាននិងផ្ដល់ព័ត៌មាន ដោយផ្សារភ្ជាប់ដំណោះស្រាយបញ្ហាជាក់ស្ដែងក្នុងសហគមន៍
- ជំរុញនិងលើកទឹកចិត្តសិស្សឱ្យចូលរួមធ្វើសកម្មភាពសិក្សាផ្សេងៗដូចជា ការចូលរួមក្នុងល្បែងសិក្សា ការដើរតួ ការឡើងធ្វើបទបង្ហាញ  តាមក្រុម និងរកអំណះអំណាង ការពារគំនិតរបស់ខ្លួន
- បង្រៀនពីងាយទៅលំបាក ពីរូបី ពាក់កណ្ដាលរូបី ទៅអរូបី និងមានភាពងាយស្រួល ចៀសវាងប្រើពាក្យពេចន៍ ដែលមិនសមស្របតាមវ័យរបស់សិស្ស
- ប្រើសម្ភារឧបទេស និងការអនុវត្តគំរូឱ្យបានជាអតិបរមា
- បង្ហាញរូបគំរូ ណែនាំសិស្សឱ្យសង្កេត និងដាក់សម្ភារៈសម្រាប់ធ្វើនៅចំពោះមុខសិស្ស
- ណែនាំសិស្សឱ្យរកសម្ភារៈ និងព័ត៌មានត្រៀមទុកមុនការបង្រៀនមេរៀន
- ជំរុញនិងលើកទឹកចិត្តដល់សិស្សឱ្យហ៊ានសួរសំណួរ និងដាក់បញ្ហាដើម្បីដោះស្រាយ
- បណ្ដុះសិស្សឱ្យចេះស្រាវជ្រាវ វិភាគ ពិចារណា សំយោគ ច្នៃប្រឌិត បង្កើតថ្មី និងអនុវត្តប្រើប្រាស់ក្នុងសហគមន៍របស់ខ្លួន។

## វិធីសាស្ត្របង្រៀន

- **គោលការណ៍ទី១៖** ការបង្រៀនផ្ដោតលើសកម្មភាពសម្របសម្រួលក្នុងការសិក្សារបស់សិស្សដើម្បីឱ្យពួកគេមានវិជ្ជាសម្បទា បំណិនសម្បទា  និងចរិយាសម្បទា ដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល។
- **គោលការណ៍ទី២៖** ការបង្រៀនផ្ដោតលើសកម្មភាពជួយ និងលើកទឹកចិត្តសិស្សឱ្យចេះពីរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងការទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្តចំណេះដឹង ដោយផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃដោយប្រើប្រាស់វិធីសាស្ត្រទំនើប ដូចជាការសហការ និងការអង្កេត។
- **គោលការណ៍ទី៣៖** ការបង្រៀនត្រូវបន្តនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគាត់ស្រឡាញ់ និងផ្ដល់តម្លៃដល់ការសិក្សា។
- **គោលការណ៍ទី៤៖** ការបង្រៀនត្រូវផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងការអនុវត្ត ក្នុងបរិស្ថានជុំវិញតាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារឧបទេសរួមទាំងបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍សម្បូរបែប និងមានបច្ចុប្បន្នភាព។

ដោយផ្អែកលើគោលការណ៍ទាំងអស់ខាងលើ គ្រូអនុវត្តវិធីសាស្ត្រផ្សេងៗដូចជា៖
- ការបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា អាចប្រព្រឹត្តទៅតាមវិធីសាស្ត្រខុសៗគ្នាអាស្រ័យលើល្បិច និងភាពប៉ិនប្រសប់របស់គ្រូ ឱ្យស្របនឹងកម្រិតបញ្ញា មជ្ឈដ្ឋាន និងជីវភាពរស់នៅរបស់សិស្ស។
- ការបង្រៀន អាចផ្ដល់ជាទ្រឹស្ដី  ការប្រតិបត្តិ  ទស្សនកិច្ចសិក្សា  ឆាកល្ខោនខ្លី  ការសម្ដែងតួ  រឿងនិទាន ឬសកម្មភាពផ្សេងទៀត ជាសកម្មភាពច្នៃប្រឌិតរស់រវើករបស់គ្រូដែលមានលក្ខណៈជាក់ស្ដែង និងការចូលរួមយ៉ាងសកម្មរបស់សិស្ស។
- ការបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ត្រូវបណ្ដុះគំនិតស្រឡាញ់វប្បធម៌ជាតិ មានឥរិយាបថល្អ ទម្លាប់ល្អសេចក្ដីថ្លៃថ្នូររបស់ខ្លួន ចេះគិតពិចារណាសមហេតុផល ជាពលរដ្ឋមិនមានការរើសអើងជាតិសាសន៍  វប្បធម៌សាសនា និងប្រត្តិបត្តិអំពីអំពើល្អស្របតាមគោលការណ៍សីលធម៌ជាតិ និងសកល។

- ការបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា គ្រូត្រូវប្រើវិធីសាស្ត្រទំនើបដូចជា វិធីពិភាក្សា វិធីសហការ វិធីសម្ភាស ធ្វើបាថកថា វិធីដោះស្រាយបញ្ហា(Problem Solving) ការសិក្សាស្រាវជ្រាវមេរៀន (Lesson Study) ការសិក្សាតាមបែបរិះរក (Inquiry Base Learning)។ ឧទាហរណ៍៖ក្នុងការបង្រៀនមុខវិជ្ជាសិក្សាសង្គម យើងក៏អាចប្រើវិធីសិក្សាតាមបែបរិះរក ដែលមាន យុទ្ធសាស្ត្រ ឆ្លើយតបយ៉ាងត្រឹមត្រូវនឹងគោលវិធីសិស្សមជ្ឈមណ្ឌល ដែលការសិក្សាផ្តល់ឱកាសឱ្យសិស្ស ត្រិះរិះពិចារណា សង្កេត និងស្រាវជ្រាវដែលមានយុទ្ធវិធីលម្អិត៤ដំណាក់កាលដូចខាងក្រោម៖

  - **ការបង្កើតស្ថានភាពបញ្ហាដោយគ្រូ ឬសិស្ស៖** គ្រូត្រួតពិនិត្យការអនុវត្តកិច្ចការស្រាវជ្រាវ កិច្ចការផ្ទះដែលបានដាក់ឱ្យសិស្សធ្វើ និងចោទសំណួរទាក់ទងទៅនឹងមេរៀនប្រចាំថ្ងៃ
  - **វិធីស្វែងរកគំនិតដើម្បីដោះស្រាយបញ្ហា អំណះអំណាង)ហេតុផល៖**(គ្រូឱ្យសិស្សធ្វើសកម្មភាព សង្កេតរូបភាពផ្សេងៗ និងធ្វើការពន្យល់បកស្រាយរូបភាព
  - **ផ្ទៀងផ្ទាត់វាយតម្លៃ(ការពន្យល់ពីអំណះអំណាងដែលប្រមូលបាន)៖** ពង្រីកខ្លឹមសារទិន្នន័យឱ្យទៅជាអនុវត្តក្នុងសហគមន៍ខ្លួនស្រាយតាមរយៈ ការវិភាគ សិក្សាប្រៀបធៀបបញ្ហាផ្សេងៗ
  - ការដោះស្រាយបញ្ហា ការសំយោគ ការសន្និដ្ឋាន សកម្មភាពផ្សព្វផ្សាយ (អំណះអំណាង ពិតប្រាកដ ទឡ្ហីករណ៍ និងជាក់លាក់សម្រាប់ការពន្យល់) ៖ សិស្សសង្ខេបខ្លឹមសារសំខាន់ៗ បន្ទាប់មកឱ្យសិស្សធ្វើការស្រាវជ្រាវឯកសារផ្សេងៗទៀតតាមរយៈកិច្ចការផ្ទះ ស្រង់ប្រមែប្រមូល ទិន្នន័យ ធ្វើជាតារាង ក្រាហ្វិច ដ្យាក្រាម ធ្វើការប្រៀបធៀប និងការស្វែងរកគំនិតបង្កើតថ្មី ។

## ៦- ការវាយតម្លៃ

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវផ្តោតលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការវាយតម្លៃជាការវាស់ស្ទង់សមត្ថភាពសិស្សដើម្បីឱ្យដឹងថា លទ្ធផលនៃការសិក្សារបស់សិស្សទទួលបានកម្រិតណា សំដៅរកព័ត៌មាន ឬភស្តុតាង ដើម្បីសន្និដ្ឋាន សម្រេចចិត្ត និងរកវិធី ផ្តល់ធាតុចូល ជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្សនិងដំណើរការបង្រៀនរបស់គ្រូដោយផ្អែកលើកម្មវិធីសិក្សាលម្អិតនិងស្តង់ដាកម្មវិធីសិក្សា នឹងជួយឱ្យដឹងថា តើលទ្ធផលសិក្សារបស់សិស្ស សម្រេចបានតាមកម្មវិធីសិក្សាលម្អិត ស្តង់ដាកម្មវិធីសិក្សាដែរឬទេ នៅពេលបង្រៀនចប់ខ្លឹមសារមេរៀននីមួយៗ។

ការវាយតម្លៃការរៀននិងបង្រៀនគឺជាដំណើរការ ជានិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងភស្តុតាងអំពីកម្រិតសមត្ថភាពសិស្ស ក្រោយពីដំណើរការរៀននិងបង្រៀន ទាំងក្នុងថ្នាក់និងក្រៅថ្នាក់ ឱ្យឆ្លើយតប លទ្ធផលសិក្សាដែលបានរំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ។

ការវាយតម្លៃត្រូវមានលក្ខណៈវិនិច្ឆ័យ សមស្របទៅនឹងកម្រិតលទ្ធផល សិក្សានៃកម្រិតថ្នាក់នីមួយៗ។

### ៦.១- សារៈសំខាន់នៃការវាយតម្លៃ

ការវាយតម្លៃនៃការសិក្សារបស់សិស្ស ជាផ្នែកដ៏សំខាន់នៃការបង្រៀន និងរៀន។ ជាទូទៅ ការវាយតម្លៃមានសារៈសំខាន់ដូចខាងក្រោម៖

- វាស់កម្រិតចំណេះដឹង បំណិន ឥរិយាបថរបស់សិស្សក្រោយពីបានសិក្សាចប់ខ្លឹមសារមេរៀន ជំពូក ឬកម្មវិធីសិក្សាតាមថ្នាក់និងតាមកម្រិតសិក្សានីមួយៗ
- វាស់កម្រិតនៃការប្រែប្រួល ឬការរីកចម្រើនផ្លូវចិត្តនិងគុណតម្លៃនានាដូចជាតម្លៃសីលធម៌ ឥរិយាបថ សាមគ្គីភាព ការស្រឡាញ់វប្បធម៌ ប្រពៃណីជាតិ។ល។
- ឆ្លុះបញ្ចាំងពីលទ្ធផលនៃការរៀន និងការបង្រៀនដោយផ្តល់ព័ត៌មានត្រឡប់ដល់គ្រូ សិស្ស មាតាបិតាឬអាណាព្យាបាលសិស្ស គណៈគ្រប់គ្រងសាលារៀន និងអ្នកអប់រំ ដើម្បីជួយរកមធ្យោបាយលើកកម្ពស់គុណភាពនៃការរៀន និងការបង្រៀនឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់
- ដើម្បីស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្ស ក្នុងគោលបំណងកែលម្អឡើងវិញឱ្យទាន់ពេលនូវសកម្មភាពរៀននិងបង្រៀន
- ដើម្បីវាយតម្លៃ និងកែលម្អកម្មវិធីសិក្សាជាដំណាក់កាលៗ
- ដើម្បីផ្តល់ទិន្នន័យដែលជួយដល់ការធ្វើសេចក្តីសម្រេចចិត្តអំពីអនាគតរបស់សិស្សក្នុងការបន្តការសិក្សា។

### ៦.២- លក្ខខណ្ឌនៃការវាយតម្លៃ

ដើម្បីឱ្យលទ្ធផលនៃការវាយតម្លៃមានប្រសិទ្ធភាព ប្រកបដោយជោគជ័យ គ្រូត្រូវកំណត់ឱ្យបានច្បាស់លាស់អំពី៖

- វត្ថុបំណងវាយតម្លៃ (ដើម្បីអ្វី)
- សមត្ថភាព ឬបំណិនដែលត្រូវវាយតម្លៃ (លើអ្វី)
- កម្រិតវាយតម្លៃ (ត្រឹមណា)
- រូបភាពវាយតម្លៃ (សំណេរ ផ្ទាល់មាត់ ការប្រតិបត្តិ ការសង្កេតផ្ទាល់)
- កាលបរិច្ឆេទវាយតម្លៃ (ពេលណា)
- រយៈពេលវាយតម្លៃ (ប៉ុន្មាននាទី ប៉ុន្មានម៉ោង)។

### ៦.៣- លំនាំនៃការវាយតម្លៃ

ការវាយតម្លៃ គឺផ្អែកតាមលំនាំដូចខាងក្រោម៖

- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ត្រូវផ្អែកតាមកម្រិតថ្នាក់នីមួយៗ
- ការវាយតម្លៃលទ្ធផលសិក្សាធៀបទៅនឹងស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត
- ការវាយតម្លៃបញ្ចប់ភូមិសិក្សា ឬប្រឡងថ្នាក់ជាតិ ។ល។

ការវាយតម្លៃ ត្រូវធ្វើឡើងដោយគ្រូបង្រៀនតាមថ្នាក់ និងមុខវិជ្ជានីមួយៗក្នុងគោលបំណងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ ដោយផ្តោតទៅលើចំណេះដឹង បំណិន និងឥរិយាថទៅតាមមេរៀននីមួយៗ។ វិធីសាស្ត្រនៃការវាយតម្លៃមានដូចជា សំណួរផ្ទាល់មាត់ និងធ្វើលំហាត់ ការពិភាក្សា ការសង្កេត កិច្ចការផ្ទះ ការប្រឡងនិងគម្រោងស្រាវជ្រាវ ដើម្បីវាយតម្លៃលទ្ធផលសិក្សាក្នុងថ្នាក់រៀននីមួយៗ។ គ្រូបង្រៀនត្រូវប្រមូលវិភាគ សំយោគ និងបកស្រាយលទ្ធផលនៃការវាយតម្លៃ ដើម្បីសម្រេចជ្រើសរើស និងកែសម្រួលវិធីសាស្ត្ររៀន និងបង្រៀន។

លទ្ធផលនៃការវាយតម្លៃនេះឆ្លុះបញ្ចាំងការបង្រៀន នឹងត្រូវប្រើប្រាស់សម្រាប់ការវាយតម្លៃសាលារៀនផងដែរ។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់នីមួយៗ ត្រូវធ្វើឡើងតាមដំណាក់ដូចតទៅ៖

- ការវាយតម្លៃជាប្រចាំ: ធ្វើឡើងក្នុងពេលកំពុងបង្រៀនមេរៀននីមួយៗ
- ការវាយតម្លៃតាមដំណាក់: ធ្វើឡើងនៅពេលបញ្ចប់ដំណាក់តូចៗនៃមេរៀនលើចំណេះដឹង បំណិន និងឥរិយាបថ

- ការវាយតម្លៃប្រចាំខែ និងប្រចាំឆមាសៈ ធ្វើឡើងនៅពេលដំណាច់ខែ ឬបញ្ចប់ឆមាសនីមួយៗនៃឆ្នាំសិក្សា។ គ្រូ និងគណៈគ្រប់គ្រង សាលារៀន គួរតែផ្តល់ការបញ្ជាក់យ៉ាងច្បាស់លាស់ដល់សិស្ស និងមាតាបិតា សិស្សឬអាណាព្យាបាលសិស្ស អំពីលទ្ធផលសិក្សាដែលសិស្សទទួលបានទៅតាមដំណាក់នីមួយៗ។ សិស្សត្រូវតែទទួលបានព័ត៌មានច្បាស់លាស់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងជំហានដែលពួកគេត្រូវអភិវឌ្ឍបន្ត ដើម្បីខិតខំបង្កើនលទ្ធផលសិក្សារបស់ពួកគេឱ្យកាន់តែល្អប្រសើរឡើង ។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៧ (៧០ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូក១៖ ខ្ញុំ និងគ្រួសារខ្ញុំ** | | ២៦ម៉ |
| **មេរៀនទី១ : គ្រួសារនិងភារកិច្ចក្នុងសង្គមអភិវឌ្ឍ**<br>១.១- និយមន័យ "គ្រួសារ " ប្រភេទគ្រួសារ<br>១.២- តួនាទីនិងភារកិច្ចរបស់សមាជិកគ្រួសារ<br>១.៣- ផលវិបាកនៃគ្រួសារតូច និងគ្រួសារធំ | **វិជ្ជាសម្បទា**<br>- ប្រាប់បាននិយមន័យ "គ្រួសារ"តាមរយៈឯកសារផ្សេងៗ<br>- ពណ៌នាប្រភេទគ្រួសារតូច និងគ្រួសារធំ។<br>**បំណិនសម្បទា**<br>- កំណត់តួនាទីនិងភារកិច្ចរបស់សមាជិកគ្រួសារនីមួយៗតាមសភាពជាក់ស្តែងនៃក្រុមគ្រួសាររបស់ខ្លួន<br>- បង្ហាញពីផលវិបាកគ្រួសារតូចនិងគ្រួសារធំតាមរយៈការពិភាក្សាក្រុម។<br>**ចរិយាសម្បទា**<br>- គោរពស្រឡាញ់យកចិត្តទុកដាក់ចំពោះសមាជិកក្រុមគ្រួសារ។ | ៤ ម៉ |
| **មេរៀនទី២ : ទំនាក់ទំនងល្អក្នុងគ្រួសារ**<br>២.១- ទំនាក់ទំនងល្អនិងសុភមង្គលក្នុងគ្រួសារ<br>២.២- ផលប្រយោជន៍នៃទំនាក់ទំនងល្អក្នុងគ្រួសារ<br>២.៣- ទំនាក់ទំនងប្រកបដោយឥរិយាបថថ្លៃថ្នូរ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីន័យ "ទំនាក់ទំនងល្អ" និង"សុភមង្គលក្នុងគ្រួសារ"<br>- ប្រាប់ពីផលប្រយោជន៍នៃទំនាក់ទំនងល្អក្នុងគ្រួសារតាមរយៈមេរៀន។<br>**បំណិនសម្បទា**<br>- កំណត់បានពីឥរិយាបថថ្លៃថ្នូរសម្រាប់ធ្វើទំនាក់ទំនងល្អក្នុងគ្រួសាររបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- គោរពនិងអនុវត្តប្រតិបត្តិតាមវិន័យក្រុមគ្រួសារខ្លួនឱ្យបានភ្ជាប់ខ្លួន<br>- ឥរិយាបថប្រកបដោយសេចក្តីថ្លៃថ្នូរក្នុងទំនាក់ទំនងជាតិ | ៤ ម៉ |

| | | |
|---|---|---|
| | និងអន្តរជាតិ។ | |
| **មេរៀនទី៣ : ការងារនិងច្បាប់ការងារ**<br>៣.១- ការស្វែងរកព័ត៌មានសម្រាប់ការងារ<br>៣.២- ជម្រើសការងារ<br>៣.៣- ច្បាប់ការងារ<br>៣.៤- សារៈសំខាន់នៃជម្រើសការងារត្រឹមត្រូវ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបស្វែងរកព័ត៌មានអំពីអាជីពណាមួយតាមរយៈប្រភពដូចជា កាសែត ទស្សនាវដ្ដី អ៊ីនធឺណែត ....។<br>- ប្រាប់បានពីទំនងរវាងច្បាប់ការងារនិងការងារ និងជម្រើសការងារត្រឹមត្រូវ។<br>**បំណិនសម្បទា**<br>- ធ្វើបទបង្ហាញសង្ខេបពីអាជីពណាមួយដល់មិត្តភក្តិ និងអ្នកជុំវិញដែលទាក់ទងនឹងជីវភាពរបស់ពួកគេ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃការងារ និងបង្កើតឱកាសការងាររបស់ខ្លួនជានិច្ច និងចាប់យកឱកាសសម្រាប់ខ្លួនឯង។ | ៤ម៉ |
| **មេរៀនទី៤ : ហេតុអ្វីបានត្រូវស្វ័យគ្រប់គ្រង**<br>៤.១- ស្វ័យគ្រប់គ្រង<br>៤.២- លក្ខណៈសម្គាល់សកម្មភាពប្រកបដោយស្វ័យគ្រប់គ្រង<br>៤.៣- សារៈសំខាន់នៃស្វ័យគ្រប់គ្រង<br>៤.៤- លក្ខណៈសម្គាល់នៃអាកប្បកិរិយាប្រកបដោយការទទួល ខុសត្រូវ និងការមិនទទួល<br>ខុសត្រូវផ្នែកហិរញ្ញវត្ថុ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអត្ថន័យ "ស្វ័យគ្រប់គ្រង"<br>- ប្រាប់បានលក្ខណៈសម្គាល់សកម្មភាពប្រកបដោយស្វ័យគ្រប់គ្រង<br>- ប្រាប់បានពីសារៈសំខាន់នៃស្វ័យគ្រប់គ្រង។<br>**បំណិនសម្បទា**<br>- កំណត់បានផែនការស្វ័យគ្រប់គ្រងលើការងារប្រចាំថ្ងៃសម្រាប់ខ្លួនឯង គ្រួសារ សាលារៀន សហគមន៍ និងផែនការការសិក្សាប្រចាំថ្ងៃ សប្ដាហ៍ ខែរបស់ខ្លួន<br>- កំណត់កិច្ចការរបស់ខ្លួន និងបែងចែកភាពខុសគ្នារវាងតម្រូវការ និងចំណង់ឱ្យសមស្របនឹងកំណើនសេដ្ឋកិច្ចគ្រួសារ។<br>**ចរិយាសម្បទា**<br>- ប្រតិបត្តិផែនការស្វ័យគ្រប់គ្រងក្នុងការងារប្រចាំថ្ងៃឱ្យបានខ្ជាប់ខ្ជួន<br>- បង្ហាញពីការរៀបចំធ្វើផែនការ និងការចាត់ចែងក្នុងការអនុវត្តផែនការជាពិសេសការចំណាយ និងសន្សំ។ | ៤ម៉ |
| **មេរៀនទី៥ : សម្ពាធផ្លូវចិត្ត**<br>៥.១- សញ្ញាណទូទៅស្ដីពីសម្ពាធផ្លូវចិត្ត<br>៥.២- មូលហេតុបណ្ដាលឱ្យមានសម្ពាធផ្លូវចិត្ត | **វិជ្ជាសម្បទា**<br>- ពន្យល់បានពី "សម្ពាធផ្លូវចិត្ត"<br>- រៀបរាប់ពីមូលហេតុបណ្ដាលឱ្យមានសម្ពាធផ្លូវចិត្ត។<br>**បំណិនសម្បទា**<br>- កំណត់សកម្មភាពត្រឹមត្រូវ និងសកម្មភាពខុសឆ្គង | ៣ម៉ |

| | | |
|---|---|---|
| ៥.៣- ផលប៉ះពាល់នៃសម្ពាធ ផ្លូវចិត្តនិងការសម្រេចចិត្ត<br>៥.៤- ដំណោះស្រាយ សម្ពាធផ្លូវចិត្ត | - ស្វែងរកវិធីជំនះ និងការដោះស្រាយសម្ពាធផ្លូវចិត្ត<br>- បដិសេធថា "ទេ" ចំពោះសកម្មភាព និងកាលៈទេសៈ ដែលមិនត្រឹមត្រូវក្នុងការធ្វើទំនាក់ទំនង។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃសកម្មភាពត្រឹមត្រូវ និងប្រកាន់គោលជំហរឹងប៉ឹង។ | |
| **មេរៀនទី៦ : មានប្រាក់មានអ្វីៗគ្រប់យ៉ាងឬទេ?**<br>៦.១- អត្ថន័យនៃអំណាចទឹកប្រាក់<br>៦.២- ការកំណត់ព្រំដែន នៃ អំណាចទឹកប្រាក់<br>៦.៣- ជម្រើសវើសមធ្យោបាយ ត្រឹមត្រូវក្នុងការប្រើប្រាស់ទឹកប្រាក់ដើម្បីជោគជ័យ ក្នុងជីវិត | **វិជ្ជាសម្បទា**<br>- ពន្យល់ពីអត្ថន័យនៃអំណាចនិងព្រំដែននៃ អំណាចទឹកប្រាក់<br>- រៀបរាប់ពីការប្រើប្រាស់អំណាច និងព្រំដែននៃទឹកប្រាក់។<br>**បំណិនសម្បទា**<br>- វែកញែកពីរបៀបប្រើប្រាស់អំណាចទឹកប្រាក់ប្រកបដោយ ការត្រិះរិះពិចារណា មិនឱ្យតម្លៃហួសហេតុលើប្រាក់ និង សម្ភារៈ<br>- ជ្រើសរើសមធ្យោបាយត្រឹមត្រូវក្នុងការប្រើប្រាស់ទឹកប្រាក់ ដើម្បីសម្រេចជោគជ័យក្នុងជីវិត។<br>**ចរិយាសម្បទា**<br>- បណ្ដុះគំនិតមិនលោភលន់ សណ្ដោស និងស្រឡាញ់ សច្ចធម៌។ | ៣ម៉ |
| **មេរៀនទី៧ : បញ្ឈប់ការប្រើប្រាស់គ្រឿងញៀន**<br>៧.១- គ្រឿងញៀនជាអ្វី?<br>៧.២- ប្រភេទនៃគ្រឿងញៀន<br>៧.៣- ផលប៉ះពាល់នៃការសេព គ្រឿងញៀន<br>៧.៤- វិធានការការពារ និង ទប់ស្កាត់គ្រឿងញៀន<br>៧.៥- តួនាទីរបស់សហគមន៍ក្នុង ការទប់ស្កាត់ការចែកចាយ និងការប្រើប្រាស់ គ្រឿងញៀន | **វិជ្ជាសម្បទា**<br>- ពន្យល់បញ្ញត្តិ"គ្រឿងញៀន"<br>- រៀបរាប់ពីប្រភេទគ្រឿងញៀន និងផលប៉ះពាល់នៃការសេព គ្រឿងញៀនចំពោះខ្លួនឯង គ្រួសារ សហគមន៍ជាតិ និង អន្តរជាតិ<br>- ប្រាប់បានវិធានការការពារនិងទប់ស្កាត់ការប្រើប្រាស់និង ជួញដូរ គ្រឿងញៀនតាមរយៈការប្រើប្រាស់រូបភាពកាសែត ទស្សនាវដ្តី សម្ភាសជនរងគ្រោះ...។<br>**បំណិនសម្បទា**<br>- កំណត់បានពីភាពអន្តរាយរបស់ខ្លួន និងការគេចឱ្យផុតពី ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន<br>- កំណត់បានពីតួនាទីសហគមន៍ក្នុងការផ្សព្វផ្សាយប្រភព ព័ត៌មានពីគ្រឿងញៀនទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងផលប៉ះពាល់គ្រឿងញៀន។<br>**ចរិយាសម្បទា**<br>- ចូលរួមធ្វើយុទ្ធនាការ ទប់ស្កាត់និងប្រឆាំងការជួញដូរ គ្រឿងញៀន | ៤ម៉ |

| | | |
|---|---|---|
| | - ណែនាំមិត្តភក្តិពីផលប៉ះពាល់នៃគ្រឿងញៀននិងប្រុងប្រយត្នខ្លួនឱ្យគេចចេញឆ្ងាយពីគ្រឿងញៀន។ | |
| **ជំពូកទី២៖ សហគមន៍ខ្ញុំ** | | ១៦ម៉ |
| **មេរៀនទី១ : មិត្តភាពនិងការសេពគប់**<br>១.១- មិត្តភាព<br>១.២- លក្ខណៈសម្គាល់ កល្យាណមិត្ត និងបាបមិត្ត<br>១.៣- ការរក្សាចំណងមិត្តភាព<br>១.៤- សារៈសំខាន់នៃចំណង មិត្តភាព | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីលក្ខណៈកល្យាណមិត្ត និងបាបមិត្ត។<br>**បំណិនសម្បទា**<br>- បង្ហាញសារៈសំខាន់នៃទំនាក់ទំនងមិត្តភាព និងទំនាក់ទំនងល្អរវាងក្មេងប្រុសនិងស្រី<br>- បង្ហាញការជ្រើសរើស ការរក្សា និងការពង្រឹងមិត្តភាពយូរអង្វែង<br>- រកវិធីអូសទាញបាបមិត្តឱ្យដើរទៅរកផ្លូវល្អ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃមិត្តភាពល្អដូចជាការយល់ចិត្តគ្នា ការការពារ ការទុកចិត្ត និងភាពស្មោះត្រង់ ជួយទុក្ខធុរៈគ្នាជានិច្ច។ | ៤ម៉ |
| **មេរៀនទី២ : ការចូលរួមបរិច្ចាគ**<br>២.១- ការបរិច្ចាគជាអ្វី? មូលហេតុអ្វីបានបរិច្ចាក?<br>២.២- ចរិតលក្ខណៈនៃការបរិច្ចាគ<br>២.៣- **ការចូលរួមបរិច្ចាគ**<br>២.៣- សារៈសំខាន់នៃការបរិច្ចាគ ក្នុងគ្រួសារ សហគមន៍ សង្គមជាតិ និង កាកកបាទក្រហម | **វិជ្ជាសម្បទា**<br>- ពន្យល់បានពីបញ្ញត្តិ "ការបរិច្ចាគ"<br>- ពណ៌នាចរិតលក្ខណៈនៃ "ការបរិច្ចាគ"<br>- រៀបរាប់សារៈសំខាន់នៃការបរិច្ចាគក្នុងគ្រួសារ សហគមន៍ កាកកបាទក្រហមសង្គមជាតិ និងអន្តរជាតិ។<br>**បំណិនសម្បទា**<br>- បង្ហាញពីការចែករំលែករបស់គ្រួសារ សហគមន៍ ដល់អ្នករងគ្រោះ និងចូលរួមរំលែកទុក្ខ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃសារៈសំខាន់នៃការបរិច្ចាគ ចូលរួមបរិច្ចាគ និងរំលែកទុក្ខដល់អ្នករងគ្រោះ។ | ៤ម៉ |
| **មេរៀនទី៣ : ការទទួលខុសត្រូវ**<br>៣.១- បញ្ញតិនៃការទទួលខុសត្រូវ<br>៣.២- លក្ខណៈសម្គាល់នៃ អាកប្បកិរិយាប្រកប ដោយការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវ<br>៣.៣- លក្ខខណ្ឌ និងការទទួល ខុសត្រូវ ផ្នែកហិរញ្ញវត្ថុ<br>៣.៤- លទ្ធផលនៃអាកប្បកិរិយា ប្រកបដោយការទទួលខុស | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីបញ្ញត្តិ "ការទទួលខុសត្រូវ"<br>- ប្រាប់ពីលក្ខណៈសម្គាល់នៃអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវ<br>- ប្រាប់ពីរបៀបសន្សំសំចៃនិងការប្រើប្រាស់លុយឱ្យមានប្រសិទ្ធភាព។<br>**បំណិនសម្បទា**<br>- រៀបចំផែនការសេដ្ឋកិច្ចគ្រួសារ<br>- បែងចែកភាពខុសគ្នារវាងអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវ។ | ៤ម៉ |

| | | |
|---|---|---|
| ត្រូវ និងការមិន<br>ទទួលខុសត្រូវ | **ចរិយាសម្បទា**<br>- ផ្តល់តម្លៃលើអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ<br>- និងធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ។<br>- មានស្មារតីទទួលខុសត្រូវលើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុតាមលក្ខខណ្ឌកំណត់។ | |
| **មេរៀនទី៤ : សុវត្ថិភាពក្នុងការធ្វើដំណើរ**<br>៤.១- ផ្លូវថ្នល់ និងយានជំនិះ<br>៤.២- ច្បាប់ចរាចរណ៍ផ្លូវគោក<br>៤.៣- ភ្លើង និងផ្លាកសញ្ញាចរាចរណ៍<br>៤.៤- ការត្រួតពិនិត្យ សុវត្ថិភាពកង់ ម៉ូតូ<br>៤.៥- ការប្រើប្រាស់ផ្លូវ និងសិទ្ធិអាទិភាព | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីប្រភេទផ្លូវ និងយានជំនិះដែលត្រូវប្រើប្រាស់ផ្លូវ<br>- ប្រាប់បានពីខ្លឹមសារនៃច្បាប់ចរាចរណ៍ផ្លូវគោក<br>- ប្រាប់អត្ថន័យអំពីភ្លើងនិងផ្លាកសញ្ញាចរាចរណ៍និងការប្រើប្រាស់ ផ្លូវថ្នល់ប្រកបដោយសុវត្ថិភាព។<br>**បំណិនសម្បទា**<br>- កំណត់បានពីវិធីនិងមធ្យោបាយក្នុងការធ្វើដំណើរឬបើកបរប្រកបដោយសុវត្ថិភាព<br>- អនុវត្តការសម្តែងតួអំពីការប្រើប្រាស់ភ្លើងផ្លាកសញ្ញា និងសញ្ញាអាទិភាព និងត្រួតពិនិត្យយានជំនិះមុនធ្វើដំណើរ...។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរពច្បាប់ចរាចរណ៍ និងប្រុងប្រយត្ន សុវត្ថិភាពជានិច្ចនៅពេលធ្វើដំណើរ។ | ៤ម៉ |
| **ជំពូកព៣ះ ទប្បធម៌ និទសាសនា** | | ១២ម៉ |
| **មេរៀនទី១ : ព្រះពុទ្ធសាសនានិងការអប់រំ**<br>១.១- សាសនាជាអ្វី?<br>១.២- ប្រភពនៃជំនឿ សាសនាព្រះពុទ្ធ<br>១.៣- ការអប់រំរបស់ព្រះពុទ្ធសាសនា<br>១.៤- តម្លៃនិងការអនុវត្តតាមពុទ្ធោវាទ<br>១.៥- ព្រះពុទ្ធសាសនានិងការអប់រំសេដ្ឋកិច្ច | **វិជ្ជាសម្បទា**<br>- ពន្យល់បញ្ញត្តិ "សាសនា"<br>- រៀបរាប់ដើមកំណើត និងសង្ខេបពីជំនឿលើព្រះពុទ្ធសាសនា<br>- រៀបរាប់ការអប់រំសំខាន់ៗរបស់ព្រះពុទ្ធសាសនាក្នុងការរស់នៅប្រចាំថ្ងៃ។<br>**បំណិនសម្បទា**<br>- អនុវត្តទ្រឹស្តីអប់រំល្អៗសម្រាប់ខ្លួន និងសង្គមជាតិ។<br>**ចរិយាសម្បទា**<br>- គោរពនិងប្រតិបត្តិតាមពុទ្ធោវាទប្រកបដោយវិចារណញ្ញាណ។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី២ : ព្រហ្មញ្ញសាសនា និងការអប់រំ**<br>២.១- ប្រភពនៃជំនឿ ព្រហ្មញ្ញសាសនា<br>២.២- ឥទ្ធិពលនៃជំនឿលើ ព្រហ្មញ្ញសាសនា<br>២.៣- ការអប់រំសំខាន់ៗរបស់ ព្រហ្មញ្ញសាសនា នៅក្នុងការរស់នៅ | **វិជ្ជាសម្បទា**<br>- រៀបរាប់ដើមកំណើតនិងជំនឿលើព្រហ្មញ្ញសាសនា<br>- រៀបរាប់ការអប់រំសំខាន់ៗរបស់ព្រហ្មញ្ញសាសនា នៅក្នុងការរស់នៅ។<br>**បំណិនសម្បទា**<br>- កំណត់បានពីឥទ្ធិព្រហ្មញ្ញសាសនាក្នុងការអនុវត្តសង្គមខ្មែរបច្ចុប្បន្ន ដូចជា វិធីសែនព្រេន អាពាហ៍ពិពាហ៍។ល។<br>- វិភាគរកចំណុចល្អ និងមិនល្អរបស់ព្រហ្មញ្ញសាសនាក្នុងការអនុវត្ត។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃនិងទទួលស្គាល់អ្នកមានជំនឿលើ ព្រហ្មញ្ញសាសនា។ | ៤ម៉ |
| **មេរៀនទី៣ : ប្រាសាទអង្គរវត្ត និងអត្តសញ្ញាណ**<br>៣.១- ប្រាសាទអង្គរវត្ត<br>៣.២- អត្ថន័យ និងរជ្ជកាលនៃ ការកសាងប្រាសាទអង្គរវត្ត<br>៣.៣- ប្រាសាទអង្គរវត្តជាអត្តសញ្ញាណនៃវប្បធម៌ជាតិ<br>៣.៤- ប្រាសាទអង្គរវត្ត និងការទាក់ទាញភ្ញៀវទេសចរ<br>៣.៥- ការការពារ និងថែរក្សា ប្រាសាទអង្គរវត្ត | **វិជ្ជាសម្បទា**<br>- ប្រាប់ពីទីតាំងប្រាសាទអង្គរវត្ត និងអត្ថន័យ នៃការសាងសង់ប្រាសាទនេះ<br>- ប្រាប់បានពីអត្ថន័យនៃការកសាង ប្រាសាទអង្គរវត្តតាមរជ្ជកាល។<br>**បំណិនសម្បទា**<br>- បង្ហាញពីសារៈសំខាន់របស់ប្រាសាទអង្គរវត្តនិង ការទាក់ទាញភ្ញៀវទេសចរ<br>- បង្កើតវិធានការចូលរួមថែរក្សានិងការពារប្រាសាទអង្គរវត្ត ឱ្យបានគង់វង្ស។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីស្រឡាញ់ ចូលរួមសកម្មភាព ថែរក្សា និងការពារប្រាសាទអង្គរវត្ត។ | ៤ម៉ |
| **ជំពូកទី៤៖ សង្គមជាតិយើង** | | ១៦ម៉ |
| **មេរៀនទី១ : យេនឌ័រនិង សិទ្ធិមនុស្ស**<br>១.១- ភេទ និងយេនឌ័រនិង សិទ្ធិមនុស្ស<br>១.២- ផ្នត់គំនិតខ្មែរនិងយេនឌ័រ<br>១.៣- តួនាទីស្ត្រីក្នុងសង្គមខ្មែរ<br>១.៤-ផលប៉ះពាល់នៃការរើសអើង និងបញ្ហាផ្លូវចិត្ត<br>១.៥-វិធានការសំខាន់ៗសម្រាប់ | **វិជ្ជាសម្បទា**<br>- កំណត់ពីនិយមន័យ "ភេទ យេនឌ័រ សិទ្ធិមនុស្ស"<br>- ប្រាប់បានពីផ្នត់គំនិតមនុស្សបច្ចុប្បន្នអំពី យេនឌ័រ<br>- ប្រាប់បានពីភាពខុសគ្នារវាង "ភេទ យេនឌ័រ និង សិទ្ធិមនុស្ស។<br>**បំណិនសម្បទា**<br>- បង្ហាញពីការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍគ្រួសារ និងសង្គម<br>- បង្ហាញពីផលប៉ះពាល់អវិជ្ជមាននៃការរើសអើងផ្នែក | ៤ម៉ |

| | | |
|---|---|---|
| ធានាសមភាពយេនឌ័រ | យេនឌ័រចំពោះនារី និងបុរស កុមារា និងកុមារី<br>- បង្កើតវិធានការសំខាន់ៗមួយចំនួនដែលបុគ្គលគ្រួសារ និងសហគមន៍ត្រូវអនុវត្ត ផ្អែកលើផ្នត់គំនិត យេនឌ័រ និងផ្តល់ឱកាសស្មើគ្នារវាងបុរស និងស្ត្រី។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃសមភាពយេនឌ័រ ផ្លាស់ប្តូរផ្នត់គំនិត ដើម្បីបង្កឱកាសស្មើគ្នារវាងបុរស និងស្ត្រី។ | |
| **មេរៀនទី២ : សញ្ញាណដំបូងនៃច្បាប់**<br>២.១- ច្បាប់ជាអ្វី?<br>២.២- ហេតុអ្វីត្រូវបង្កើតច្បាប់?<br>២.៣- សារៈសំខាន់នៃការ បង្កើតច្បាប់ និងការគោរពច្បាប់ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យទូទៅ "ច្បាប់"<br>- ពន្យល់មូលហេតុដែលនាំឱ្យមានការបង្កើតច្បាប់<br>- រៀបរាប់មូលហេតុនៃការបង្កើតច្បាប់ និងការគោរពច្បាប់។<br>**បំណិនសម្បទា**<br>- កំណត់បានពីសារៈសំខាន់នៃការអនុវត្ត និងការគោរពច្បាប់។<br>**ចរិយាសម្បទា**<br>- គោរពច្បាប់ និងចូលរួមអនុវត្តច្បាប់ជាប្រចាំ។ | ៤ម៉ |
| **មេរៀនទី៣ : ការបង្ការនិងបញ្ឈប់ការបៀតបៀនផ្លូវភេទ**<br>៣.១- ការបៀតបៀនផ្លូវភេទ<br>៣.២- ប្រភេទនិងមូលហេតុនៃការបៀតបៀនផ្លូវភេទ<br>៣.៣- ការដាក់ពាក្យបណ្តឹង<br>៣.៤- វិធីបង្ការនិងបញ្ឈប់ការបៀតបៀនផ្លូវភេទ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីអត្ថន័យនៃការបៀតបៀនផ្លូវភេទ បណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌ<br>- រៀបរាប់ប្រភេទនិងផលប៉ះពាល់នៃការបៀតបៀនផ្លូវភេទ និងប្រភេទនិងគោលបំណងនៃបណ្តឹង។<br>**បំណិនសម្បទា**<br>- កំណត់បានភាគីជម្លោះនៃបណ្តឹងតាមរយៈការបំពេញទម្រង់បណ្តឹងរដ្ឋប្បវេណី និងព្រហ្មទណ្ឌក្នុងករណីសិក្សា<br>- បំពេញបែបបទនៃពាក្យបណ្តឹងផ្សេងៗ<br>- រកឃើញវិធីបង្ការនិងការចូលរួមបញ្ឈប់ការបៀតបៀនផ្លូវភេទ។<br>**ចរិយាសម្បទា**<br>- ចូលរួមផ្សព្វផ្សាយវិធីបង្ការនិងបញ្ឈប់ការបៀតបៀនផ្លូវភេទ និងអនុវត្តច្បាប់។ | ៤ម៉ |
| **មេរៀនទី៤ : ការបោះឆ្នោតនិងកាតព្វកិច្ចរបស់ពលរដ្ឋ**<br>៤.១- សញ្ញាណទូទៅស្តីពីការបោះឆ្នោត | **វិជ្ជាសម្បទា**<br>- ពន្យល់បញ្ញត្តិ និងគោលបំណងនៃការបោះ ឆ្នោត<br>- ពណ៌នាពីប្រភេទនិងដំណើរការនៃការបោះឆ្នោត<br>- ប្រាប់បានពីការបោះឆ្នោតសកល និងអសកល។ | ៥ម៉ |

| | | |
|---|---|---|
| ៤.២- គោលបំណងនៃការបោះឆ្នោត<br>៤.៣- ប្រភេទនិងដំណើរការនៃការបោះឆ្នោត<br>៤.៤- ការបោះឆ្នោតសកល និងអសកល | **បំណិនសម្បទា**<br>- ពិភាក្សាពីគុណសម្បត្តិ និងគុណវិបត្តិនៃដំណើរការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន តាមរយៈអនុវត្តការបោះឆ្នោតជ្រើសរើសប្រធានថ្នាក់<br>- រកភាពខុសគ្នារវាងការបោះឆ្នោតសកល និងអសកល ដូចជា ការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំសង្កាត់ និងការបោះឆ្នោត តំណាងរាស្ត្រនិងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្ត ក្រុងស្រុក ខណ្ឌ និងការជ្រើសរើសសមាជិក ព្រឹទ្ធសភា។<br>**ចរិយាសម្បទា**<br>- គោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យនិងចូលរួមអនុវត្តការបោះឆ្នោតតាមកាលកំណត់។ | |

## ៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៨ (៧០ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូក១៖ ខ្ញុំ និងគ្រួសារខ្ញុំ** | | ២៦ម៉ |
| **មេរៀនទី១ : សិទ្ធិនិងអនុសញ្ញាកុមារ**<br>១.១- សញ្ញាណទូទៅស្តីពីសិទ្ធិកុមារ<br>១.២- ប្រភេទសិទ្ធិរបស់កុមារ<br>១.៣- សិទ្ធិនិងករណីយកិច្ចរបស់កុមារ<br>១.៤- មូលហេតុនៃការបង្កើត សិទ្ធិកុមារ<br>១.៥- ផលប៉ះពាល់នៃ ការបោះបង់ចោលកុមារ<br>១.៦- ការចូលរួមគាំពារសិទ្ធិកុមារ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យ "សិទ្ធិកុមារ" និងសិទ្ធិកុមារសំខាន់ៗទាំង៤<br>- ប្រាប់បានពីសិទ្ធិ និងករណីយកិច្ចដែលកុមារត្រូវធ្វើ។<br>**បំណិនសម្បទា**<br>- ស្វែងរកដំណោះស្រាយ និងប៉ះពាល់នៃការបោះបង់កូនចៅរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាល<br>- រកឃើញវិធីល្អៗក្នុងការថែទាំខ្លួននៅពេលមានការបោះបង់។<br>**ចរិយាស ម្បទា**<br>- ចូលរួមគាំពារ និងយកចិត្តទុកដាក់ដល់អ្នកដែលគេបោះបង់ និងកាត់បន្ថយអត្រាការបោះបង់ចោលកុមារ។ | ៤ម៉ |
| **មេរៀនទី២ : សិទ្ធិរស់នៅក្នុងសេចក្តីថ្លៃថ្នូរ**<br>២.១- សញ្ញាណទូទៅស្តីពីសិទ្ធិ<br>២.២- សិទ្ធិសំខាន់ៗរបស់ ជនពិការ<br>២.៣- ផលប៉ះពាល់នៃការរើស | **វិជ្ជាសម្បទា**<br>- រៀបរាប់សញ្ញាណសិទ្ធិនិងសិទ្ធិសំខាន់ៗរបស់ជនពិការ និងសមត្ថភាពរបស់ជនពិការក្នុងការចូលរួមអភិវឌ្ឍជាតិ<br>- រៀបរាប់ផលប៉ះពាល់នៃការរើសអើងចំពោះជីវភាពរស់នៅរបស់ជនពិការ។ | ៤ម៉ |

| | | |
|---|---|---|
| អើងចំពោះជនពិការ<br>២.៤- សារៈសំខាន់នៃការ គោរពសិទ្ធិ និងទំនាក់ទំនងល្អ រវាង បុគ្គល ក្រុម សង្គម និង ប្រទេសជាតិ | **បំណិនសម្បទា**<br>- កំណត់បានពីវិធីការការពារសិទ្ធិចំពោះជនពិការនិង ការចូលរួម ជនពិការក្នុងសហគមន៍និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។<br>- កំណត់បានពីសារៈសំខាន់នៃការ គោរពសិទ្ធិ និងទំនាក់ទំនងល្អ រវាងបុគ្គល ក្រុម សង្គម និងប្រទេសជាតិ។<br>**ចរិយាសម្បទា**<br>- ចូលរួមអនុវត្តគោរពសិទ្ធិមនុស្សនិងសិទ្ធិជនពិការ។ | |
| **មេរៀនទី៣ : ការឯកភាព ក្នុងគ្រួសារ**<br>៣.១- ការឯកភាពក្នុង គ្រួសារ<br>៣.២- ធនធាននិងទំហំនៃគ្រួសារ<br>៣.៣- ក្រមសីលធម៌ក្នុង គ្រួសារ<br>៣.៤- ទំនាក់ទំនងនិងភាព ស្មោះត្រង់ក្នុងគ្រួសារ<br>៣.៥- ទំនាក់ទំនងក្នុងគ្រួសារ និងអ្នកជិតខាង<br>៣.៦- តម្លៃក្នុងគ្រួសារ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអត្ថន័យ ការឯកភាពក្នុងគ្រួសារ និង ក្រមសីលធម៌ក្នុងគ្រួសារ និងទំនាក់ទំនងល្អក្នុងគ្រួសារ។<br>- រៀបរាប់ការទំនាក់ទំនងល្អសមាជិកគ្រួសារនិង ភាពស្មោះត្រង់ក្នុងគ្រួសារនិងអ្នកជិតខាង ។<br>**បំណិនសម្បទា**<br>- បង្ហាញសារៈសំខាន់នៃភាពស្មោះត្រង់របស់សមាជិកម្នាក់ៗ ចំពោះគ្រួសារនិងអ្នកជិតខាងខ្លួន<br>- បកស្រាយពីផលល្អនៃការឯកភាពគ្នាក្នុងគ្រួសារ និង ជិតខាង។<br>**ចរិយាសម្បទា**<br>- គោរពស្រឡាញ់សមាជិកក្នុងគ្រួសារ និងអ្នកខាងដើម្បី ភាពសុខសាន្ត។ | ៣ម៉ |
| **មេរៀនទី៤ : ភាពសុខដុម ក្នុងគ្រួសារ**<br>៤.១- និយមន័យ "សុខដុម"<br>៤.២- កត្តានិងសកម្មភាព នាំឱ្យមានភាពសុខដុម ក្នុងគ្រួសារ<br>៤.៣- សារៈសំខាន់និងភាព សុខដុមក្នុងសង្គម<br>៤.៤- មូលហេតុនិងផលវិបាក នៃទំនាស់ក្នុងគ្រួសារ<br>៤.៥- ការដោះស្រាយទំនាស់ ដោយសន្តិវិធី | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យ "ភាពសុខដុម"<br>- ពន្យល់ពីកត្តាដែលនាំឱ្យកើតមានភាពសុខដុមនៅក្នុង គ្រួសារ និងសង្គមជាតិ<br>- ប្រាប់បានពីមូលហេតុនិងផលវិបាកនៃទំនាស់ក្នុងគ្រួសារ។<br>**បំណិនសម្បទា**<br>- បង្ហាញពីវិធីសុខចិត្ត សុខកាយ និងកសាងកម្លាំងចិត្តរឹងមាំ<br>- បង្ហាញពីវិធីការរក្សាភាពសុខដុមក្នុងគ្រួសារ<br>- បង្ហាញមូលហេតុនៃជម្លោះ និងរកវិធីទប់ស្កាត់ទំនាស់<br>- បង្ហាញពីការដោះស្រាយទំនាស់ដោយសន្តិវិធីរបស់សិស្ស ម្នាក់ៗ ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃខ្ពស់លើភាពសុខដុមក្នុងគ្រួសារ សង្គមជាតិ និង សកលលោក | ៣ម៉ |

| | | |
|---|---|---|
| | - បង្កើនការយកចិត្តទុកដាក់និងគោរពស្រឡាញ់ ក្រុមគ្រួសារ សហគមន៍ និងប្រជាជាតិដទៃ។ | |
| **មេរៀនទី៥ : ជម្រើសត្រឹមត្រូវនិងការសម្រេចចិត្ត**<br>៥.១- សញ្ញាណស្តីពី អាកប្បកិរិយា<br>៥.២- ប្រភេទនៃអាកប្បកិរិយានិងការសម្តែងអាកប្បកិរិយា<br>៥.៣- ជម្រើសនៃការសម្តែងអាក្បកិរិយា និងគុណតម្លៃ<br>៥.៤- ការសម្រេចចិត្តត្រឹមត្រូវ<br>៥.៥- ហ៊ាននិយាយថាទេ ចំពោះទង្វើមិនត្រឹមត្រូវ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យ "អាកប្បកិរិយា"<br>- ប្រាប់បានប្រភេទអាកប្បកិរិយាសមរម្យ និងមិនសមរម្យ។<br>**បំណិនសម្បទា**<br>- បែងចែករវាងអាកប្បកិរិយាដែលសង្គមទទួលយក និងសង្គមបដិសេធ<br>- រកឃើញគន្លឹះសំខាន់ៗដែលជំរុញឱ្យមានការជ្រើសយកជម្រើសដែលត្រឹមត្រូវ<br>- សម្តែងតួ "ហ៊ាននិយាយថាទេ "ចំពោះអ្វីដែលមិនត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រកាន់ខ្ជាប់នូវឥរិយាបថ វិជ្ជមាននានាដែលសង្គមទទួលស្គាល់។ | ៤ម៉ |
| **មេរៀនទី៦ : ការចូលរួមបង្ការ ទប់ស្កាត់ បទល្មើស**<br>៦.១- តើបទល្មើសគឺជាអ្វី?<br>៦.២- សកម្មភាពបទល្មើស និងទោសទណ្ឌ<br>៦.៣- សកម្មភាពបង្ការ និងទប់ស្កាត់បទល្មើស<br>៦.៤- ផលប្រយោជន៍ក្នុងការបង្ការនិងទប់ស្កាត់បទល្មើស | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីសកម្មភាពជាបទល្មើស<br>- កំណត់សកម្មភាពមុខសញ្ញាដើម្បីបង្ការ និងទប់ស្កាត់បទល្មើសផ្សេងៗដែលកើតឡើងក្នុងសង្គមខ្មែរ។<br>**បំណិនសម្បទា**<br>- ពិភាក្សារកវិធីបង្ការ និងទប់ស្កាត់ សកម្មភាពបទល្មើស<br>- បង្ហាញពីផលប្រយោជន៍ក្នុងការបង្ការ និងទប់ស្កាត់បទល្មើស<br>- បង្ហាញពីមូលហេតុក្នុងការអនុវត្តច្បាប់តាមរយៈករណីសិក្សាណាមួយផ្សារភ្ជាប់ក្នុងជីវភាពជាក់ស្តែងរៀងៗខ្លួន។<br>**ចរិយាសម្បទា**<br>- ចូលរួមក្នុងការបង្ការ និងទប់ស្កាត់បទល្មើសព្រមទាំងអនុវត្តច្បាប់បានត្រឹមត្រូវ។ | ៤ម៉ |
| **មេរៀនទី៧ : យុត្តិធម៌ និងអយុត្តិធម៌**<br>៧.១- អំពើស្របច្បាប់ មិនស្របច្បាប់ យុត្តិធម៌ និងអយុត្តិធម៌<br>៧.២- ផលប៉ះពាល់នៃអំពើខុសច្បាប់ និងអយុត្តិធម៌<br>៧.៣- វិធីដោះស្រាយផ្សេងៗ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីនិយមន័យ យុត្តិធម៌ និងអយុត្តិធម៌ ដោយផ្អែកលើរូបភាព និងឯកសារផ្សេងៗ។<br>**បំណិនសម្បទា**<br>- ពិភាក្សាពីផលប៉ះពាល់ដែលបណ្តាលមកពីអំពើខុសច្បាប់និងអយុត្តិធម៌ក្នុងសង្គម។<br>- រកវិធីផ្សព្វផ្សាយបង្ការ ទប់ស្កាត់ និងដោះស្រាយអំពើខុសច្បាប់ក្នុងសង្គម។ | ៤ម៉ |

| | | |
|---|---|---|
| ក្នុងការដោះស្រាយបញ្ហា<br>អយុត្តិធម៌ | **ចរិយាសម្បទា**<br>- ចូលរួមការពារសកម្មភាពស្របច្បាប់និងយុត្តិធម៌<br>- ប្រកាន់ខ្ជាប់នូវដំណោះស្រាយបញ្ហាប្រកបដោយយុត្តិធម៌។ | |
| **ជំពូក២៖ សហគមន៍ខ្ញុំ** | | ១៦ម៉ |
| **មេរៀនទី១ : សុវត្ថិភាពជាតិផ្ទុះក្នុងសហគមន៍**<br>១.១- សុវត្ថិភាពទូទៅក្នុងសហគមនី<br>១.២- សញ្ញាណស្ដីពីអាវុធជាតិផ្ទុះ<br>១.៣- ប្រភេទអាវុធ ជាតិផ្ទុះ<br>១.៤- ច្បាប់ពាក់ព័ន្ធ និងការប្រើប្រាស់អាវុធជាតិផ្ទុះ<br>១.៥- ផលប៉ះពាល់ និងវិធីបង្ការទប់ស្កាត់អាវុធជាតិផ្ទុះ<br>១.៦- ការចូលរួមទទួលខុសត្រូវសុវត្ថិភាពក្នុងសហគមន៍ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីសុវត្ថិភាពក្នុងសហគមន៍ និងសញ្ញាណនៃអាវុធជាតិផ្ទុះ<br>- រៀបរាប់ពីប្រភេទ និងគ្រោះថ្នាក់នៃអាវុធជាតិផ្ទុះ<br>- ប្រាប់បានពីបទបញ្ញត្តិ ច្បាប់ផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់អាវុធជាតិផ្ទុះ<br>**បំណិនសម្បទា**<br>- ពិភាក្សារកផលប៉ះពាល់ក្នុងការប្រើប្រាស់អាវុធជាតិផ្ទុះមកលើកុមារ គ្រួសារ និងសហគមន៍។<br>- រកឃើញពីវិធីបង្ការ និងទប់ស្កាត់ការប្រើប្រាស់អាវុធជាតិផ្ទុះក្នុងសហគមន៍<br>- ចូលរួមផ្សព្វផ្សាយ ធ្វើយុទ្ធនាការ និងប្រឆាំងការប្រើប្រាស់អាវុធជាតិផ្ទុះ។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្ន និងចូលរួមអនុវត្តច្បាប់ ដើម្បីសុវត្ថិភាពសហគមន៍។ | ៤ម៉ |
| **មេរៀនទី២៖សុវត្ថិភាពចរាចរណ៍ក្នុងសហគមន៍**<br>២.១- សញ្ញាណស្ដីពីគ្រោះថ្នាក់ចរាចរណ៍<br>២.២- កត្តាដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍<br>២.៣- ផលប៉ះពាល់ដែលបណ្ដាលមកពីគ្រោះថ្នាក់ចរាចរណ៍<br>២.៤- ការចូលរួមទទួលខុសត្រូវសុវត្ថិភាពក្នុងសហគមន៍ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីគ្រោះថ្នាក់ចរាចរណ៍<br>- ប្រាប់បានពីមូលហេតុផ្សេងៗដូចជា ផ្លូវ មនុស្ស ស្លាកសញ្ញាច្បាប់ ដែលបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍<br>- ពន្យល់ផលប៉ះពាល់ដែលបណ្ដាលមកពីគ្រោះថ្នាក់ចរាចរណ៍។<br>**បំណិនសម្បទា**<br>- កត់ត្រាទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ក្នុងសហគមន៍<br>- រិះរកវិធីប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍នៅតាមសហគមន៍<br>- រកមធ្យោបាយផ្សព្វផ្សាយការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ដូចជាធ្វើបណ្ណផ្ទត់....។<br>**ចរិយាសម្បទា**<br>- ចូលរួមចំណែកបង្ការ ទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍<br>- មានស្មារតីប្រុងប្រយ័ត្នក្នុងពេលធ្វើដំណើរ ដើម្បីសុវត្ថិភាព | ៤ម៉ |

| | | |
|---|---|---|
| | អាយុជីវិតខ្លួនឯង និងអ្នកដទៃ។ | |
| **មេរៀនទី៣ ៖ ការទទួលខុសត្រូវក្នុងការបើកបរ**<br>៣.១- ការអធ្យាស្រ័យក្នុងការបើកបរ<br>៣.២- ច្បាប់ចរាចរណ៍ផ្លូវគោក<br>៣.៣- ការទទួលខុសត្រូវក្នុងពេលបើកបរ<br>៣.៤- សារៈសំខាន់នៃការគោរពច្បាប់ក្នុងពេលបើកបរ | **វិជ្ជាសម្បទា**<br>- ពណ៌នាអាកប្បកិរិយាប្រកបដោយសុជីវធម៌ និងការចេះអត់ធ្មត់ក្នុងការបើកបរ<br>- រៀបរាប់ពីច្បាប់ចរាចរណ៍ដែលចែងអំពីការទទួលខុសត្រូវរបស់អ្នកបើកបរ។<br>**បំណិនសម្បទា**<br>- កំណត់ពីសារៈសំខាន់នៃសកម្មភាពដែលប្រកបដោយសុជីវធម៌ និងការទទួលខុសត្រូវរបស់អ្នកបើកបរ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់នូវការគោរពច្បាប់ចរាចរណ៍ក្នុងពេលបើកបរ។ | ៤ម៉ |
| **មេរៀនទី៤: ស្មារតីចូលរួមរៀបចំផែនការ**<br>៤.១- ផែនការ និងការរៀបចំ<br>៤.២- ដំណើរការរៀបចំផែនការសកម្មភាព<br>៤.៣- សារៈសំខាន់នៃផែនការនិងការអនុវត្តសកម្មភាព<br>៤.៤- ការរៀបចំផែនការហិរញ្ញវត្ថុ | **វិជ្ជាសម្បទា**<br>- ពន្យល់បានពីដំណើរការនៃការធ្វើផែនការ និងការរៀបចំចាត់ចែង។<br>**បំណិនសម្បទា**<br>- រៀបចំផែនការសកម្មភាពការងារប្រកបដោយការទទួលខុសត្រូវ<br>- កសាងផែនការនិងរៀបចំសកម្មភាពការងារប្រចាំថ្ងៃ ខែ ឆ្នាំ<br>- វាយតម្លៃសកម្មភាពក្នុងសាលារៀនប្រចាំថ្ងៃ ខែ ឆ្នាំ<br>- ធ្វើផែនការការងារប្រកបដោយការទទួលខុសត្រូវ តម្លាភាព ការចូលរួម ទាំងសកម្មភាព ទាំងហិរញ្ញវត្ថុ។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់កសាងផែនការ និងអនុវត្តសកម្មភាពតាមគម្រោងផែនការរបស់ខ្លួន។ | ៤ម៉ |
| **ជំពូកព៣៖ វប្បធម៌ និងសាសនា** | | ១២ម៉ |
| **មេរៀនទី១ : ល្បែងប្រជាប្រិយខ្មែរ**<br>១.១- ដូចម្តេចដែលហៅថាល្បែងប្រជាប្រិយ?<br>១.២- ប្រភេទនិងប្រវត្តិនៃល្បែងប្រជាប្រិយខ្មែរ<br>១.៣- អត្ថន័យ និងសារៈសំខាន់នៃល្បែងប្រជាប្រិយខ្មែរ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យល្បែងប្រជាប្រិយខ្មែរ<br>- រៀបរាប់ពីប្រភេទនិងប្រវត្តិល្បែងប្រជាប្រិយខ្មែរដែលគេនិយមលេងក្នុងកម្មវិធីបុណ្យប្រពៃណីផ្សេងៗ ។<br>**បំណិនសម្បទា**<br>- ពិភាក្សាពីអត្ថន័យ និងសារៈសំខាន់នៃល្បែងប្រជាប្រិយខ្មែរ<br>- បង្ហាញពីរបៀបលេងល្បែងប្រជាប្រិយខ្មែរ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ចូលរួមថែរក្សាការពារ និងលេងល្បែងប្រជាប្រិយខ្មែរក្នុងកម្មវិធីបុណ្យប្រពៃណីជាតិ។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី២ : ជំនឿគ្រិស្តសាសនា និងឥស្លាមសាសនា**<br>២.១- ដើមកំណើតគ្រិស្តសាសនា និងឥស្លាមសាសនា<br>២.២- ការអប់រំតាមបែបគ្រិស្តសាសនា និងឥស្លាមសាសនា<br>២.៣- សារៈសំខាន់នៃការអប់រំរបស់គ្រិស្តសាសនា និងឥស្លាម សាសនា | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីដើមកំណើតដោយសង្ខេបនៃគ្រិស្តសាសនា និងឥស្លាមសាសនា<br>- ពណ៌នាការអប់រំសំខាន់ៗនៃគ្រិស្តសាសនា និងឥស្លាមសាសនា។<br>**បំណិនសម្បទា**<br>- រកឃើញគោលជំនឿលើគ្រិស្តសាសនា និងឥស្លាមសាសនា និងការអនុវត្តក្នុងសហគមន៍ខ្លួន។<br>**ចរិយាសម្បទា**<br>- ប្រកាន់យកការអប់រំដែលមិនប្រាសចាសពីគោលការណ៍ល្អនៃសាសនានីមួយៗ<br>- គោរពជំនឿសាសនារបស់អ្នកដទៃ។ | ៤ម៉ |
| **មេរៀនទី៣ : ពិធីបុណ្យសពក្នុងប្រទេសកម្ពុជា**<br>៣.១- សញ្ញាណទូទៅស្តីពីពិធីបុណ្យសព<br>៣.២- ការរៀបចំ និងដំណើរការនៃពិធីបុណ្យសពតាមទំនៀមទម្លាប់<br>៣.៣- សារៈសំខាន់នៃពិធីបុណ្យសពនៅក្នុងសង្គមខ្មែរ និងជាតិសាសន៍ដទៃ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបធ្វើបុណ្យ និងទំនៀមទម្លាប់ក្នុងពិធីបុណ្យសព<br>- ពន្យល់ពីអត្ថន័យនៃពិធីបុណ្យសព។<br>**បំណិនសម្បទា**<br>- បែងចែកសកម្មភាពតាមលំដាប់លំដោយនៃដំណើរការក្នុងពិធីតាមទំនៀមទម្លាប់។<br>**ចរិយាសម្បទា**<br>- ចូលរួមការពារ និងថែរក្សាទំនៀមទម្លាប់ប្រពៃណីជាតិនីមួយៗ។ | ៤ម៉ |
| **ជំពូក៤៖ សង្គមជាតិយើង** | | ១៦ម៉ |
| **មេរៀនទី១ : ភាពផ្សេងៗគ្នានៃអត្តសញ្ញាណជាតិ**<br>១.១- អ្វីទៅជាអត្តសញ្ញាណជាតិ?<br>១.២- អត្តសញ្ញាណជនជាតិខ្មែរ<br>១.៣- អត្តសញ្ញាណជនជាតិផ្សេងៗ<br>១.៤- ភាពខុសគ្នា និងគុណតម្លៃអត្តសញ្ញាណជាតិសាសន៍នានា | **វិជ្ជាសម្បទា**<br>- កំណត់បានពីអត្តសញ្ញាណជាតិខ្មែរ និងអត្តសញ្ញាណជាតិសាសន៍ផ្សេងៗ។<br>**បំណិនសម្បទា**<br>- បង្ហាញពីអត្តសញ្ញាណជនជាតិខ្មែរ និងអត្តសញ្ញាណជនជាតិផ្សេងៗ<br>- រកឃើញភាពខុសគ្នារវាងអត្តសញ្ញាណជាតិខ្លួន និងអត្តសញ្ញាណជាតិដទៃ។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃអត្តសញ្ញាណជាតិខ្លួន និងអត្តសញ្ញាណជាតិសាសន៍ដទៃ<br>- ចូលរួមថែរក្សាអត្តសញ្ញាណជាតិខ្លួនឱ្យបានគង់វង្ស។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី២ : ការអនុវត្តច្បាប់**<br>២.១.- ច្បាប់ជាអ្វី?<br>២.២- ច្បាប់មានប្រភពមកពីណា?<br>២.៣- ទិដ្ឋភាពទូទៅនៃច្បាប់<br>២.៤- ការអនុម័ត និងការអនុវត្តច្បាប់<br>២.៥- សារៈសំខាន់នៃការអនុវត្តច្បាប់ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យរបស់ពាក្យ "ច្បាប់" ក្នុងកម្រិតទូលាយ<br>- ពន្យល់បានពីប្រភព និងទិដ្ឋភាពនៃច្បាប់។<br>**បំណិនសម្បទា**<br>- វិភាគរកមូលហេតុដែលសង្គមបង្កើតច្បាប់ និងអនុវត្តច្បាប់<br>- បង្ហាញពីសារៈសំខាន់នៃការអនុវត្តច្បាប់។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃនិងចូលរួមគោរពច្បាប់ អនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ។ | ៤ម៉ |
| **មេរៀនទី៣ : សាលាដំបូង រាជធានី ខេត្ត**<br>៣.១- រចនាសម្ព័ន្ធសាលាដំបូង រាជធានីខេត្ត<br>៣.២- សមាសភាព និងតួនាទី របស់មន្ត្រីសាលាដំបូង<br>៣.៣- សារៈសំខាន់នៃការបំពេញ មុខងាររបស់សាលាដំបូង | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រព័ន្ធតុលាការ សមាសភាព សមត្ថកិច្ច និង តួនាទីមន្ត្រីសាលាដំបូង។<br>**បំណិនសម្បទា**<br>- បង្ហាញសិទ្ធិ និងដំណើរការដាក់ពាក្យបណ្ដឹងទៅតុលាការ សាលាដំបូង។<br>**ចរិយាសម្បទា**<br>- ចូលរួមគោរពច្បាប់ និងអនុវត្តច្បាប់បានត្រឹមត្រូវ។ | ៤ម៉ |
| **មេរៀនទី៤ : នគរបាលយុត្តិធម៌**<br>៤.១- សមាសភាពនៃនគរបាល យុត្តិធម៌ និងមន្ត្រីនគរបាល យុត្តិធម៌<br>៤.២- តួនាទី និងភារកិច្ចនគរបាល យុត្តិធម៌<br>៤.៣- កាតព្វកិច្ចរបស់នគរបាល យុត្តិធម៌ក្នុងកិច្ចការសន្តិភាព សុខសុវត្ថិភាពប្រជាជន<br>៤.៤- ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងនគរបាលយុត្តិធម៌ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីសមាសភាពនៃនគរបាលយុត្តិធម៌<br>- ពន្យល់បានពីតួនាទី ភារកិច្ច និងសមាសភាពនៃនគរបាល យុត្តិធម៌។<br>**បំណិនសម្បទា**<br>- បង្ហាញពីទំនាក់ទំនងប្រជាពលរដ្ឋនឹងនគរបាលយុត្តិធម៌ ក្នុងការ<br>- អនុវត្តច្បាប់ដូចជាការបំពេញបែបបទ លិខិតគតិយុត ផ្សេងៗ...។<br>**ចរិយាសម្បទា**<br>- ចូលរួមសហការជាមួយនគរបាលយុត្តិធម៌ក្នុងការអនុវត្ត ច្បាប់។ | ៤ម៉ |

## ៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី៩ (៧០ម៉ោង)

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូក១៖ ខ្ញុំ និងគ្រួសារខ្ញុំ** | | **២៦ម៉** |
| **មេរៀនទី១ : កិច្ចការពារខ្លួនខ្ញុំ**<br>១.១- មូលដ្ឋានគ្រឹះនៃសិទ្ធិកុមារ<br>១.២- ការអនុវត្តសិទ្ធិកុមារ និង ល្បិចកលជនខិលខូច<br>១.៣- សកម្មភាពបោកបញ្ឆោត<br>១.៤- វិធីការពារខ្លួន និងការឆ្លើយបដិសេធទៅនឹងការបបួល | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីតម្រូវការ និងកម្រងសិទ្ធិធំៗទាំងបួនរបស់កុមារ<br>- រៀបរាប់ពីសកម្មភាពនៃការបបួលដែលនាំឱ្យមានគ្រោះថ្នាក់ផ្សេងៗ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីវិធីការពារខ្លួន ចៀសវាងការបបួលលួងលោមឆបោកពីជនខិលខូច<br>- ជ្រើសរើសវិធីការពារខ្លួន និងការឆ្លើយបដិសេធ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីប្រុងប្រយត្ន័ចំពោះការបបួលលួងលោម និងចូលរួមគោរព និងអនុវត្តសិទ្ធិកុមារ។ | ៣ម៉ |
| **មេរៀនទី២ : ការគោរពអ្នកដទៃ**<br>២.១- តម្លៃរបស់មនុស្ស និង ឥរិយាបថចំពោះអ្នកដទៃ<br>២.២- មូលហេតុនៃការគោរព ការរើសអើង និងទោសកំហុស<br>២.៣- ឥរិយាបថដែលគួរឱ្យគោរពរាប់អាន<br>២.៤- ផលប៉ះពាល់នៃការរើសអើង | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីតម្លៃមនុស្ស និង ឥរិយាបថរបស់បុគ្គលចំពោះអ្នកដទៃ<br>- រៀបរាប់ពីរូបភាពនៃការរើសអើងចំពោះអ្នកដទៃដូចជា អាយុ ភេទ ពណ៌សម្បុរ ជាតិសាសន៍....<br>- រៀបរាប់ទោសកំហុសដែលទាក់ទងនឹងការរើសអើង និងការញុះញង់ឱ្យមានការរើសអើង។<br>**បំណិនសម្បទា**<br>- បង្ហាញពីផលប៉ះពាល់នៃការរើសអើងចំពោះសមត្ថភាពផ្លូវកាយ និងសេចក្ដីថ្លៃថ្នូរទៅលើជីវភាពរស់នៅ<br>- ស្វែងរកវិធីបង្កើនការលើកស្ទួយនិងលុបបំបាត់ការរើសអើង។<br>**ចរិយាសម្បទា**<br>- គោរពស្រឡាញ់ និងឱ្យតម្លៃដល់អ្នកដទៃ។ | ៣ម៉ |
| **មេរៀនទី៣ : ទំនាក់ទំនងល្អក្នុងគ្រួសារ**<br>៣.១- ការបង្កើតគ្រួសារ<br>៣.២- លក្ខណៈសម្បត្តិរបស់ម្ដាយឪពុកក្នុងការគ្រប់គ្រងគ្រួសារ<br>៣.៣- ករណីយកិច្ចរបស់កូន | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីលក្ខណៈសម្បត្តិម្ដាយឪពុកក្នុងការគ្រប់គ្រងគ្រួសារ និងករណីយកិច្ចកូនចំពោះអ្នកមានគុណ<br>- ប្រាប់ពីមូលហេតុទំនាស់ និងដំណោះស្រាយដោយសន្តិវិធីក្នុងក្រុមគ្រួសារ<br>- រៀបរាប់ពីផលប៉ះពាល់នៃការបោះបង់គ្រួសារ។ | ៤ម៉ |

| | | |
|---|---|---|
| ចំពោះអ្នកមានគុណ<br>៣.៤- ទំនាស់ក្នុងគ្រួសារ និង ដំណោះស្រាយ<br>៣.៥- ដំបូន្មានម្ដាយឪពុក<br>៣.៦- ផលប៉ះពាល់នៃការបោះបង់គ្រួសារ<br>៣.៧- ផលប៉ះពាល់នៃការចំណាកស្រុក | **បំណិនសម្បទា**<br>- សម្ដែងតួពីស្ថានភាពផ្សេងៗគ្នារវាងសមាជិកគ្រួសារដែលស្ដាប់ដំបូន្មានឪពុកម្ដាយ និងមិនស្ដាប់បង្គាប់ឪពុកម្ដាយ<br>- ពិភាក្សា និងរាយការណ៍ពីផលវិបាកដែលអាចកើតមានចំពោះជម្រើសក្នុងស្ថានភាពផ្សេងគ្នា<br>- បង្ហាញផលប៉ះពាល់នៃការបោះបង់គ្រួសារនិងចំណាកស្រុក។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ និងលើកកម្ពស់ជីវភាព និងផ្ដល់តម្លៃគ្រួសារ<br>- បណ្ដុះស្មារតីចូលរួមស្រឡាញ់ ការពារថែរក្សាទំនាក់ទំនងគ្រួសារ។ | |
| **មេរៀនទី៤ : ការងារ និងរបបសន្តិសុខសង្គម**<br>៤.១- គោលដៅការងារ<br>៤.២- រដ្ឋបាលការងារ<br>៤.៣-លក្ខខណ្ឌការងារ និង ការបណ្ដុះបណ្ដាល<br>៤.៤- សីលធម៌និងមនសិការវិជ្ជាជីវៈ<br>៤.៥. សារៈសំខាន់នៃក្រមសីលធម៌វិជ្ជាជីវៈ<br>៤.៦- លក្ខខណ្ឌនៃរបបបេឡាសន្តិសុខសង្គម<br>៤.៦- កិច្ចសន្យាការងារ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីគោលដៅ និងលក្ខខណ្ឌការងារដែលខ្លួនស្វែងរក<br>- ពន្យល់ពីតម្រូវការវគ្គបណ្ដុះបណ្ដាលឬការសិក្សាជំនាញបន្តសម្រាប់អភិវឌ្ឍសមត្ថភាព<br>- រៀបរាប់ពីតម្លៃការងារដែលខ្លួនបំពេញប្រកបដោយមនសិការ និងក្រមសីលធម៌វិជ្ជាជីវៈ។<br>**បំណិនសម្បទា**<br>- កំណត់គោលដៅ និងការសម្រេចចិត្តរបស់ខ្លួនក្នុងការជ្រើសរើសអាជីពសមស្របតាមសមត្ថភាពខ្លួន<br>- បង្ហាញពីការសម្រេចចិត្តក្នុងការជ្រើសរើសយកអាជីពណាមួយសំរាប់ខ្លួន<br>- បំពេញបែបបទចូលបម្រើការងារដែលខ្លួនជ្រើសរើស<br>- កំណត់បានពីសារៈសំខាន់របបបេឡាសន្តិសុខសង្គម។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃលើការសម្រេចចិត្តរបស់ខ្លួននិងមានការច្នៃប្រឌិតបង្កើតឱកាសការងារសម្រាប់ខ្លួន<br>- ប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ ការបំពេញការងាររបស់ខ្លួន។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី៥ : សុចរិតភាព**<br>៥.១- អ្វីជាសុចរិតភាព?<br>៥.២- ចរិតលក្ខខណៈនៃការប្រកាន់យកសុចរិតភាព<br>៥.៣- ទស្សនៈរបស់ព្រះពុទ្ធដែលទាក់ទងនឹងសុចរិតធម៌<br>៥.៤- ទំនាក់ទំនងរវាងសុចរិតភាព និងទុច្ចរិតភាព<br>៥.៥- ផលនៃការប្រកាន់យកសុចរិតភាព | **វិជ្ជាសម្បទា**<br>- ពន្យល់ពាក្យ "សុចរិតភាព"<br>- រៀបរាប់ពីចរិតលក្ខខណៈនៃការប្រកាន់យកសុចរិតភាព<br>- ពន្យល់បានពីទំនាក់ទំនងរវាងសុចរិតភាព និងទុច្ចរិតភាព<br>- ប្រាប់បានពីទស្សនៈ ឬការអប់រំរបស់ព្រះពុទ្ធសាសនាដែលទាក់ទងនឹងសុចរិតធម៌។<br>**បំណិនសម្បទា**<br>- បង្ហាញពីទង្វើ ឬសកម្មភាពដែលប្រកបដោយសុចរិតភាព និងទុច្ចរិតភាពផ្សារភ្ជាប់នឹងស្ថានភាពជាក់ស្តែង។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់នូវទង្វើ និងការវិនិច្ឆ័យជ្រើសរើសយកសុចរិតភាពសម្រាប់ជីវិតនិងសង្គម។ | ៤ម៉ |
| **មេរៀនទី៦ : ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ**<br>៦.១- អ្វីជា "អំពើពុករលួយ"?<br>៦.២- លក្ខណៈ និងសកម្មភាពនៃអំពើពុករលួយ<br>៦.៣- ផលវិបាកនៃអំពើពុករលួយ<br>៦.៤- ស្ថាប័នប្រឆាំងអំពើពុករលួយ | **វិជ្ជាសម្បទា**<br>- ពន្យល់ពីសញ្ញាណទូទៅនៃការប្រឆាំងអំពើពុករលួយ។<br>**បំណិនសម្បទា**<br>- កំណត់បានពីសកម្មភាពជាទង្វើនៃអំពើពុករលួយ និងមិនប្រព្រឹត្តអំពើពុករលួយ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្អាតស្អំ ក្នុងការផ្តល់ចំណេះដឹង ឧត្តមគតិស្តីពីការប្រឆាំងអំពើពុករលួយ និងយល់ដឹងពីស្ថាប័នប្រឆាំងអំពើពុករលួយ។ | ៤ម៉ |
| **មេរៀនទី៧ : ការរក្សាសុវត្ថិភាពផ្ទាល់ខ្លួន**<br>៧.១- អ្វីជា "សុវត្ថិភាពចរាចរណ៍"?<br>៧.២- ការធ្វើដំណើរដោយសុវត្ថិភាព<br>៧.៣- ការពិន័យ និងការផ្តន្ទាទោស | **វិជ្ជាសម្បទា**<br>- រៀនរាប់ពីសុវត្ថិភាពចរាចរណ៍ និងការធ្វើដំណើរប្រកបដោយសុវត្ថិភាព។<br>- រៀបរាប់ពីការអនុវត្តច្បាប់ ពិន័យ និងការផ្តន្ទាទោសចំពោះការរំលោភបំពានច្បាប់ចរាចរណ៍ផ្លូវគោក<br>- ពន្យល់បានពីរបៀបផ្ទុកទំនិញ មនុស្ស និងការប្រើភ្លើង សូរស័ព្ទយានជំនិះឱ្យបានត្រឹមត្រូវ និងការចតយានយន្តដោយសុវត្ថិភាព។<br>**បំណិនសម្បទា**<br>- កំណត់ឥរិយាបថដែលមានសុវត្ថិភាពនៅពេលបើកបរ<br>- ត្រួតពិនិត្យផ្នែកផ្សេងៗនៃទោចក្រយានយន្តជាប្រចាំ<br>- កំណត់បានពីការផ្ទុកទំនិញនិងមនុស្ស ព្រមទាំងការចតដោយសុវត្ថិភាព និងការប្រើភ្លើងសូរស័ព្ទយានជំនិះត្រឹមត្រូវ<br>- អនុវត្តល្បឿនក្នុងការបើកបរ ការជែងនៅពេលបើកបរ | ៤ម៉ |

| | | |
|---|---|---|
| | ទោចក្រយានយន្តឱ្យមានសុវត្ថិភាព។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយត្នជាប់ជានិច្ចចំពោះសុវត្ថិភាពក្នុងធ្វើដំណើរ<br>- គោរពច្បាប់ចរាចរណ៍ និងមានសុជីវធម៌ជានិច្ចក្នុងការបើកបរ។ | |
| **ជំពូក២៖ សហគមន៍ខ្ញុំ** | | ១៦ម៉ |
| **មេរៀនទី១ : ឥរិយាបថខ្មែរ**<br>១.១- ការប្រតិបត្តិទំនៀមទម្លាប់ប្រពៃណីខ្មែរ<br>១.២- ការធ្វើទំនាក់ទំនងបែបពលរដ្ឋសកល<br>១.៣- ឥទ្ធិពលនៃការគោរពតាមបែបបស្ចឹមប្រទេស<br>១.៤- ទំនាក់ទំនងល្អក្នុងគ្រួសារ<br>១.៥- តម្លៃនៃឥរិយាបថខ្មែរ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីទំនៀមទម្លាប់ប្រពៃណីជាតិនៅពេលជួបគ្នា និងលក្ខណៈសកល<br>- រៀបរាប់ពីឥទ្ធិពលជំរុញអោយមានទំនាក់ទំនងល្អរវាងគ្នានឹងគ្នា។<br>**បំណិនសម្បទា**<br>- បង្ហាញពីភាពផ្សេងៗគ្នានៃទំនាក់ទំនងល្អរវាងជាតិខ្មែរ និងជាតិសាសន៍នានា<br>- បង្ហាញពីឥរិយាបថដ៏ល្អរបស់ខ្មែរដែលនាំឱ្យមានទំនាក់ទំនងល្អរវាងមនុស្ស និងមនុស្សក្នុងសង្គម។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃក្នុងទំនាក់ទំនងល្អរវាងជាតិសាសន៍ផ្សេងៗគ្នា<br>- ប្រកាន់ខ្ជាប់នូវឥរិយាបថថ្លៃថ្នូររបស់ខ្មែរ។ | ៤ម៉ |
| **មេរៀនទី២ : ទំនាក់ទំនងមិត្តភាព**<br>២.១- មិត្តភាព<br>២.២- ការកសាង និងការថែរក្សាមិត្តភាព<br>២.៣- ប្រភេទ និងលក្ខណៈនៃមិត្តភាព<br>២.៤- មិត្តភាព និងទំនាស់<br>២.៥- កត្តាដែលមានឥទ្ធិពលមកលើចំណងមិត្តភាព<br>២.៦- ផលវិបាកនិងដំណោះស្រាយទំនាស់ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីការកសាង និងថែរក្សាចំណងមិត្តភាព<br>- រៀបរាប់ផលវិបាកនៃទំនាស់ដែលអាចកើតឡើងក្នុងចំណងមិត្តភាព<br>- ប្រាប់ពីមូលហេតុដែលមានទំនាស់ចំពោះមិត្តភាព។<br>**បំណិនសម្បទា**<br>- បង្ហាញពីដំណោះស្រាយ និងជម្រើសប្រកបដោយភាតរភាព ដើម្បីថែរក្សាទំនាក់ទំនងមិត្តភាព<br>- ពិភាក្សានិងរាយការណ៍ពីផលវិបាកដែលអាចកើតមានចំពោះជម្រើស ក្នុងស្ថានភាពទាំងនោះនិងផលប៉ះពាល់ផ្សេងៗទៅលើមិត្តភាពដូចជាបង្កើតនិងសម្តែងឈុតខ្លីបង្ហាញពីស្ថានភាពផ្សេងៗគ្នា ដែលមានឥទ្ធិពលលើមិត្តភាព៖ ការចេះជួយគ្នាក្នុងគ្រាលំបាក ការបង្កទំនាស់ដោយសារការដណ្ដើមរបស់ផ្សេងៗ<br>- ពិភាក្សាស្ថានភាពដែលមានឥទ្ធិពលលើទំនាក់ទំនងមិត្តភាពរវាងមិត្តស្រីនិងមិត្តប្រុស។ | ៤ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- ស្រឡាញ់រាប់អានគ្នា ជួយដោះស្រាយបញ្ហា ទុក្ខធុរៈគ្នា ជួយ គ្នាក្នុងគ្រាមានអាសន្ន។ | |
| **មេរៀនទី៣ : ការយល់ដឹងពីលទ្ធិប្រជាធិបតេយ្យ**<br>៣.១- អ្វីជា "ប្រជាធិបតេយ្យ"?<br>៣.២- ប្រភេទនៃប្រជាធិបតេយ្យ<br>៣.៣- គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ<br>៣.៤- លក្ខណៈប្រជាធិបតេយ្យ<br>៣.៥- របបគ្រប់គ្រងក្នុងលិទ្ធិប្រជាធិបតេយ្យ<br>៣.៦- សារៈសំខាន់នៃការបោះឆ្នោតក្នុងសង្គមប្រជាធិបតេយ្យ<br>៣.៧- សារប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ<br>៣.៨- ការជ្រើសរើសថ្នាក់ដឹកនាំ<br>៣.៩- សម្លេងនៃការបោះឆ្នោត | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យ "ប្រជាធិបតេយ្យ"<br>- ពណ៌នាគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ<br>- ពន្យល់ពីតួនាទីគណបក្សនយោបាយនៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ<br>- ពន្យល់បានពីរបៀបអនុវត្តគោលការណ៍និងសារៈសំខាន់លទ្ធិប្រជាធិបតេយ្យនៅក្នុងការបោះឆ្នោត។<br>**បំណិនសម្បទា**<br>- ពិភាក្សាពីលក្ខណៈ ដំណើរការនៃលទ្ធិប្រជាធិបតេយ្យ និងសារៈប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ<br>- បង្ហាញ និងពន្យល់ពីគោលការណ៍ចំបងមួយចំនួននៃលទ្ធិប្រជាធិបតេយ្យ<br>- បង្ហាញមូលហេតុនៃការគោរពច្បាប់ជាចម្បងក្នុងសង្គមលទ្ធិប្រជាធិបតេយ្យ<br>- បង្ហាញពីតួនាទីនិងភារកិច្ចរបស់បក្សប្រឆាំងនៅក្នុងសភានៃសង្គមប្រកាន់លទ្ធិប្រជាធិបតេយ្យ។<br>**ចរិយាសម្បទា**<br>- ចូលរួមលើកកម្ពស់ និងអនុវត្តលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។ | ៤ម៉ |
| **មេរៀនទី៤ : ភាពជាអ្នកដឹកនាំ**<br>៤.១- អត្ថន័យភាពជាអ្នកដឹកនាំ<br>៤.២- ប្រភេទ និងបែបបទនៃការដឹកនាំ<br>៤.៣- មុខងាររបស់អ្នកដឹកនាំ<br>៤.៤- ការទទួលខុសត្រូវ និងប្រសិទ្ធភាពនៃការដឹកនាំ<br>៤.៥- ការដឹកនាំនិងការចូលរួមក្នុងសហគមន៍<br>៤.៦- សារៈសំខាន់ភាពជាអ្នកដឹកនាំ | **វិជ្ជាសម្បទា**<br>- ពន្យល់ពីអត្ថន័យនៃ "អ្នកដឹកនាំ" និង "ភាពជាអ្នកដឹកនាំ"<br>- រៀបរាប់ពីកិច្ចការសំខាន់របស់អ្នកដឹកនាំ<br>- រៀបរាប់ពីប្រភេទ និងបែបបទនៃការដឹកនាំ<br>- ពណ៌នាពីគំរូនៃអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពនៅក្នុង<br>- ស្ថានភាពផ្សេងៗដូចជាក្នុងគ្រួសារ សហគមន៍ ក្រុមកីឡា អង្គការ និងប្រទេសជាតិ។<br>**បំណិនសម្បទា**<br>- បង្ហាញពីរបៀបដឹកនាំ និងរចនាសម្ព័ន្ធក្នុងការដឹកនាំរបស់សហគមន៍ មូលដ្ឋាន និងការទទួលខុសត្រូវរបស់អ្នកដឹកនាំមូលដ្ឋាន<br>- បង្ហាញលក្ខណៈសម្បត្តិរបស់អ្នកដឹកនាំល្អប្រកបដោយប្រសិទ្ធភាព។ | ៤ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ការចូលរួមជ្រើសរើសថ្នាក់ដឹកនាំតាមលក្ខណៈលទ្ធិប្រជាធិបតេយ្យ។ | |
| **ជំពូក៣៖ វប្បធម៌ និងសាសនា** | | ១២ម៉ |
| **មេរៀនទី១ : ពិធីបុណ្យបែបសាសនានិងប្រពៃណី**<br>១.១- គោលបំណង និងអត្ថន័យនៃពិធីបុណ្យបែបសាសនា<br>១.២- គោលបំណង និងអត្ថន័យនៃពិធីបុណ្យបែបប្រពៃណី<br>១.៣- ដំណើរការ និងការរៀបចំពិធីបុណ្យ<br>១.៤- ឥទ្ធិពលនៃពីធីបុណ្យបែបសាសនា និងការអប់រំ<br>១.៥- ទំនាក់ទំនងរវាងសិទ្ធិមនុស្ស និងព្រះពុទ្ធសាសនា | **វិជ្ជាសម្បទា**<br>- រៀបរាប់ពិធីបុណ្យផ្សេងៗបែបសាសនាក្នុងសង្គមខ្មែរ ដែលតែងតែប្រារព្ធជារៀងរាល់ឆ្នាំដូចជា បុណ្យមាឃបូជា ពិសាខបូជា ភ្ជុំបិណ្ឌ ចូលឆ្នាំ កឋិនទាន អុំទូក អកអំបុក សំពះព្រះខែ<br>- រៀបរាប់ពីដំណើរការរៀបចំពិធីបុណ្យនីមួយៗ។<br>**បំណិនសម្បទា**<br>- អនុវត្តជំនឿផ្សេងៗដែលជាទំនៀមទម្លាប់របស់ខ្មែរ<br>- បកស្រាយភាពអវិជ្ជមានដែលតែងតែកើតឡើងក្នុងពិធីបុណ្យនីមួយៗ<br>- ពិភាក្សាទំនាក់ទំនងរវាងសិទ្ធិមនុស្ស និងពុទ្ធសាសនា។<br>**ចរិយាសម្បទា**<br>- ឱ្យតម្លៃពីសារៈសំខាន់នៃពិធីបុណ្យប្រពៃណីជាតិ<br>- ចូលរួមសម្មភាពក្នុងពិធីបុណ្យបែបសាសនារបស់ខ្មែរ<br>- ស្រឡាញ់ ថែរក្សា ការពារ ពិធីបុណ្យបែបសាសនា។ | ៤ម៉ |
| **មេរៀនទី២ : អាពាហ៍ពិពាហ៍និងការសម្រេចចិត្ត**<br>២.១- អ្វីជា អាពាហ៍ពិពាហ៍?<br>២.២- ទំនៀមទម្លាប់នៃអាពាហ៍ពិពាហ៍និងការសម្រេចចិត្ត<br>២.៣- សិទ្ធិ និងច្បាប់ក្នុងការរៀបអាពាហ៍ពិពាហ៍<br>២.៤- សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ | **វិជ្ជាសម្បទា**<br>- រៀបរាប់អត្ថន័យនៃពាក្យអាពាហ៍ពិពាហ៍<br>- ពណ៌នាលក្ខខណ្ឌផ្សេងៗដែលបុរស និងស្ត្រីអាចរៀបអាពាហ៍ពិពាហ៍<br>- រៀបរាប់ពីសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ<br>- រៀបរាប់លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជាជាមួយជនបរទេស។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីអត្ថន័យ និងគោលបំណងនៃការរៀបអាពាហ៍ពិពាហ៍<br>- បង្ហាញកាតព្វកិច្ចរបស់ម្តាយឪពុកចំពោះកូនសម្រេចចិត្តជ្រើសរើសគូស្រករ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ថែរក្សាប្រពៃណីទំនៀមទម្លាប់របស់ជាតិ។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី៣ : ប្រាសាទតាព្រហ្ម និងបន្ទាយក្ដី និង អត្តសញ្ញាណជាតិ**<br>៣.១.- ប្រាសាទតាព្រហ្ម និង បន្ទាយក្ដី<br>៣.២- អត្ថន័យនៃការកសាង ប្រាសាទតាមរជ្ជកាល<br>៣.៣- ប្រាសាទតាព្រហ្ម និង បន្ទាយក្ដីជាអត្តសញ្ញាណ នៃវប្បធម៌ជាតិ<br>៣.៤- ប្រាសាទប្រាសាទតាព្រហ្ម និងបន្ទាយក្ដីនិងការ ទាក់ទាញភ្ញៀវទេសចរ<br>៣.៥- ការការពារ និងថែរក្សា ប្រាសាទអង្គរវត្ត | **វិជ្ជាសម្បទា**<br>- រកព័ត៌មានដែលប្រាប់ឈ្មោះប្រាសាទអង្គរវត្ត និងអត្ថន័យ នៃការសាងសង់ប្រាសាទ<br>- ប្រាប់បានអត្ថន័យ មេត្តា ករុណា មុទិតា ឧបេក្ខា<br>- ប្រាប់បានពីសារៈសំខាន់ប្រាសាទអង្គរវត្តនិងការ ទាក់ទាញភ្ញៀវទេសចរ។<br>**បំណិនសម្បទា**<br>- បង្ហាញឈ្មោះប្រាសាទដែលមានក្នុងសហគមន៍របស់ខ្លួន<br>- កំណត់បានពីវិធីថែរក្សាការពារប្រាសាទអង្គរវត្តឱ្យបាន គង់វង្ស<br>- បង្កើតវិធានការចូលរួមថែរក្សាប្រាសាទអង្គរវត្ត។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតី ចូលរួមសកម្មភាពស្រឡាញ់ ថែរក្សា និងការពារប្រាសាទអង្គរវត្ត។ | ៤ម៉ |
| **ជំពូក៤៖ សង្គមជាតិយើង** | | **១៦ម៉** |
| **មេរៀនទី១ : សិទ្ធិមនុស្ស និងការរស់នៅបច្ចុប្បន្ន**<br>១.១- អ្វីជា "សិទ្ធិមនុស្ស"?<br>១.២- មូលហេតុនៃការបង្កើតសិទ្ធិ មនុស្ស<br>១.៣- គោលការណ៍សំខាន់ៗនៃ សិទ្ធិមនុស្ស<br>១.៤- កតិកាសញ្ញា និងអនុសញ្ញា អន្តរជាតិស្ដីពីសិទ្ធិមនុស្ស<br>១.៥- ការចូលរួមការពារ និងការ គោរពសិទ្ធិមនុស្ស | **វិជ្ជាសម្បទា**<br>- រៀបរាប់អត្ថន័យនៃសិទ្ធមនុស្ស<br>- រៀបរាប់ពីមូលហេតុនៃការបង្កើតសិទ្ធិមនុស្ស<br>- រៀបរាប់បានពីបំណែងចែកនៃសិទ្ធិមនុស្ស សិទ្ធិធម្មជាតិ របស់មនុស្ស<br>- រៀបរាប់បានពីព្រះពុទ្ធសាសនានិងសិទ្ធិមនុស្ស។<br>**បំណិនសម្បទា**<br>- បង្ហាញពីរបៀបប្រើសិទ្ធរបស់ខ្លួនក្នុងការការពារខ្លួន ការកាន់កាប់ ការធ្វើ ឬការទាមទារអ្វីមួយ<br>- បង្ហាញពីអត្ថន័យនៃសិទ្ធិមនុស្សនិងប្រវត្តិរបស់សិទ្ធិ មនុស្ស។<br>**ចរិយាសម្បទា**<br>- ចូលរួមសកម្មភាពការគោរពសិទ្ធិមនុស្សនិងអនុវត្តការ គោរពសិទ្ធិរបស់ខ្លួន។ | ៤ម៉ |
| **មេរៀនទី២ : សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ**<br>២.១- និយមន័យសិទ្ធិ និង ករណីយកិច្ច<br>២.២- សិទ្ធិផ្ទាល់ខ្លួនរបស់ពលរដ្ឋ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យពីសិទ្ធិ និងករណីយកិច្ច<br>- យល់ពីប្រភេទនៃសិទ្ធិរបស់ពលរដ្ឋដូចជាសិទ្ធិនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌<br>- រៀបរាប់បានពីសិទ្ធិក្នុងការចូលរួមកសាងសង្គមតាមវិស័យ | ៤ម៉ |

| | | |
|---|---|---|
| ២.៣- ករណីយកិច្ចប្រជាពលរដ្ឋក្នុងការអនុវត្តច្បាប់ | នានា<br>- យល់ពីករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងអនុវត្តច្បាប់ ដូចជា កិច្ចការពារសិទ្ធិរបស់ខ្លួន ការគោរពសិទ្ធិអ្នកដទៃ ការចូលរួម អភិវឌ្ឍសង្គម។<br>**បំណិនសម្បទា**<br>- កំណត់បានពីសិទ្ធិ និងករណីកិច្ចដើម្បីចូលរួមកិច្ចការក្នុងសង្គមនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌<br>- ប្រាប់ពីសិទ្ធិទទួលព័ត៌មានផ្នែកហិរញ្ញវត្ថុដូចជាការខ្ចីសងបំណុល ការដាក់ប្រាក់បញ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុ<br>- ពន្យល់ពីសិទ្ធិ និងការទទួលខុសត្រូវ ក្នុងនាមជាអ្នកទទួលឥណទាន។<br>**ចរិយាសម្បទា**<br>- ចូលរួមអនុវត្តសិទ្ធិនិងករណីយកិច្ចរបស់ខ្លួនជាពលរដ្ឋម្នាក់ៗ។ | |
| **មេរៀនទី៣ : លក្ខខណ្ឌនៃកិច្ចសន្យានិងច្បាប់ការងារ**<br>៣.១- និយមន័យ កិច្ចសន្យាការងារ<br>៣.២- ប្រភេទការងារ និងកម្មករនិយោជិត<br>៣.៣- ប្រភេទកិច្ចសន្យាការងារ<br>៣.៤- លក្ខខណ្ឌនៃការចូលបម្រើការងារ<br>៣.៥- ការរំលាយកិច្ចសន្យាការងារ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអត្ថន័យនៃកិច្ចសន្យាការងារ និងប្រភេទកិច្ចសន្យាការងារ ដែលមានដូចជា កិច្ចសន្យាការងារមានកំណត់ថិរវេលា កិច្ចសន្យាការងារមិនមានថិរវេលា និង កិច្ចសន្យាសាកល្បងការងារ<br>- ប្រាប់បានពីលក្ខខណ្ឌនៃការចូលបម្រើការងារមានដូចជា ការងារសម្រាប់ក្មេង ការងារសម្រាប់ស្ត្រី ដោយមិនមានការរើសអើង។<br>**បំណិនសម្បទា**<br>- កំណត់បានពីលក្ខខណ្ឌការងារសម្រាប់យុវជន និងការងារសម្រាប់ស្ត្រី<br>- កំណត់បានពីតួនាទីរបស់នយោជក និងនយោជិត<br>- រៀបរាប់ពីតម្លៃការងារដែលខ្លួនបំពេញប្រកបដោយមនសិការ និងសីលធម៌វិជ្ជាជីវៈ។<br>**ចរិយាសម្បទា**<br>- មានស្មារតីគោរពច្បាប់ការងារ និងប្រុងប្រយត្ន នៅពេលធ្វើការងារ ដើម្បីចៀសផុតពីគ្រោះថ្នាក់ផ្សេងៗ។ | ៤ម៉ |
| **មេរៀនទី៤ : សហគមន៍អាស៊ាន**<br>៤.១- ប្រទេសក្នុងសហគមន៍អាស៊ាន<br>៤.២- មូលហេតុនៃការបង្កើត | **វិជ្ជាសម្បទា**<br>- រៀបរាប់ឈ្មោះប្រទេសដែលជាសមាជិកសហគមន៍អាស៊ាន<br>- រៀបរាប់ពីមូលហេតុបង្កើតសហគមន៍អាស៊ាន | ៤ម៉ |

| | | |
|---|---|---|
| សហគមន៍អាស៊ាន<br>៤.៣- គោលការណ៍ដោះស្រាយទំនាស់របស់សមាជិកអាស៊ាន<br>៤.៤- ផលប្រយោជន៍នៃការចូលជាសមាជិកអាស៊ានរបស់កម្ពុជា<br>៤.៥- លិខិតបទដ្ឋានសំខាន់ៗក្នុងសហគមន៍អាស៊ាន | - ពន្យល់ផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍អាស៊ាន<br>- ប្រាប់បានពីប្រភេទរូបិយបណ្ណនៃប្រទេសក្នុងសមាគមន៍អាស៊ាន។<br>**បំណិនសម្បទា**<br>- សម្តែងតួពីប្រទេសជាសមាជិកសហគមន៍អាស៊ាន<br>- សម្តែងតួពីការចូលរួមរបស់ប្រទេសដែលជាសមាជិកសហគមន៍អាស៊ានក្នុងការកសាងសន្តិភាពក្នុងសហគមន៍។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់គោលការណ៍សហគមន៍ និងធ្វើកិច្ចសហប្រតិបត្តិការគ្រប់វិស័យ<br>- ប្រកាន់ខ្ជាប់ដំណោះស្រាយសន្តិភាពក្នុងការដោះស្រាយជម្លោះនានាក្នុងតំបន់។ | |

## ៨- ឯកសារយោង


- គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ ២០០៥ ដល់ ២០០៩
- កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅឆ្នាំ ២០០៦
- កម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅឆ្នាំ ២០០៦
- កម្មវិធីសិក្សាប្រទេសសិង្ហបុរីឆ្នាំ ២០១២
- កម្មវិធីសិក្សាលម្អិតអាស៊ានឆ្នាំ ២០១២
- ASEAN Curriculumn Sourcebook ២០១២
- ការអប់រំភាពជាពលរដ្ឋសកល ប្រធានបទ និងវត្ថុបំណងនៃការសិក្សា UNESCO 2015
- សៀវភៅសិក្សាសង្គមថ្នាក់ទី៧ដល់ថ្នាក់ទី៩ឆ្នាំ ២០០៧
- ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយសម្រាប់មធ្យមសិក្សាបឋមភូមិឆ្នាំ ២០១៦
- ការអប់រំស្តីពីសុវត្ថិភាពចរាចរណ៍បឋមសិក្សាឆ្នាំ ២០០៥
- សៀវភៅកម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៧៥-១៩៧៩ (មជ្ឈមណ្ឌលឯកសារកម្ពុជា)
- ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេសឆ្នាំ ២០១៥
- សុវភាធម៌ឆ្នាំ១៩៦០

## ៩. បញ្ជីឈ្មោះគណៈកម្មការ

### គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

៣- លោកជំទាវ **ឃុន រចនា**

៤- ឯកឧត្តម **ពុត សាមិត្ត**

៥- លោកបណ្ឌិត **ម៉ុក សារ៉ុម**

៦- ឯកឧត្តមបណ្ឌិត **ស៊ិន សេងហុក**

៧- លោក **អោ សៀម**

### គណៈកម្មការរៀបចំកម្មវិធីសិក្សាលម្អិត

១- ឯកឧត្តមបណ្ឌិត **ស៊ិន សេងហុក**

២- លោកបណ្ឌិត **ម៉ុក សារ៉ុម**

៣- លោក **ឡុច ចាន់ថន**

៤- លោក **ប៉ូវ វី**

៥- លោកស្រី **នូ ចន្ទី**

៦- លោកបណ្ឌិត **ចៅ លិន**

៧- លោក **ង៉ែត ធឿន**

៨- លោក **មាស ជុតិមា**

៩- លោក **ប៉េង ទិត្យសុទ្ធី**

១០- លោក **ទែន គឹមតុន**

១១- លោកបណ្ឌិត **កាង ស៊ុងឆាង**

១២- លោក **ញឹម បាក់ងន**

១៣- លោក **សាម សារុំ**

១៤- លោក **ឡេង បូរី**

១៥- លោក **ប្រាក់ ពៅ**

១៦- លោក **ផ្លុង តូន**

១៧- លោក **ឃិន វណ្ណី**

១៨- លោក **បាន កក្កដា**

១៩- លោក **ជុំ សាម**

២០- លោកស្រី **ខូវ សោភ័ណ**

២១- លោក **សំ សែន**

២២- លោក **លុយ ឡែម**

២៣- លោក **លឹម សិរីវុឌ្ឍី**

២៤- លោក **ជា សៅវ៉ាន់ថន**

## គណៈកម្មការត្រួតពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ**

៣- ឯកឧត្តមបណ្ឌិត **ជេត ជាលី**

៤- លោកបណ្ឌិត **ម៉ុក សារ៉ុម**

៥- លោក **យិន ធី**

៦- លោក **យឹម សារិន**

៧- លោក **ស៊ុន ប៊ុណ្ណា**

៨- លោក **វ៉ា វុទ្ធី**

## លេខាធិការដ្ឋាន

១- លោកបណ្ឌិត **ម៉ុក សារ៉ុម**

២- លោកបណ្ឌិត **ជ័យ ចាន់អឿន**

៣- លោកបណ្ឌិត **ឃុន គឹមលាង**

៤- លោកបណ្ឌិត **ម៉ម សុជាតិ**

៥- លោក **អុន ស៊ីវុធថា**

៦- លោក **យិន ធី**

៧- លោក **យឹម សារិន**

៨- លោក **ហាក់ ធម្មតា**

៩- លោកស្រី **វ៉ាន់ លីណា**

## ជំនួយការបច្ចេកទេសកុំព្យូទ័រ

១- លោក **លឹម សុត្ថារិទ្ធ**

២- លោក **អេង វណ្ណារិទ្ធ**

៣- លោក **មឿន លិនណា**

៤- លោក **ជួន ចេវ**

**ចរិយាសម្បទា**

អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម
សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ
ការទទួលខុសត្រូវ
កាយសុខភាព
ចិត្តសុខភាព

**វិជ្ជាសម្បទា**

អក្ខរសាស្ត្រ
លេខសាស្ត្រ
ភាសាបរទេស
បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍

**បំណិនសម្បទា**

បំណិនពិចារណានិងការបង្កើតថ្មី
ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម
អនុវត្តចំណេះដឹងនិងជំនាញ